June-2009.qxd 5/30/2009 10:10 AM Page 1


# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣០ ខែមិថុនា ឆ្នាំ២០០៩ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ២២


ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

## មាតិកា



**អ្នកជំនាញ: យុវជនមិនមែនជាឧក្រិដ្ឋជន**

ទំព័រ ៥



**អ្នកជំនាញ : "កសិករដល់ពេលដាំដុះដីហើយ"**

ទំព័រ ៩



**អង្គុយបត់ជើងបញ្ជាក់ថា...**

ទំព័រ ១៧

# ប្រជាជនក្រីក្រ ក៏មានសិទ្ធិទទួលបានសុភមង្គល ដូចអ្នកដទៃដែរ



តាំងពីថ្ងៃទី២៤ មករា ឆ្នាំ២០០៩មក ប្រជាជនមួយចំនួន ជាង១០០០នាក់ ដែលមកតាំងទីលំនៅនៅតំបន់អនាធិបតេយ្យដីក្រហមត្រូវបានអាជ្ញាធរឲ្យទៅរស់នៅខាងមុខបុរីសន្តិភាព នៅភូមិដំណាក់ទ្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ តើការរស់នៅរបស់ពួកគាត់មានស្ថានភាពបែបណាហើយនាពេលសព្វថ្ងៃនេះ? ទំព័រទី១០_១១






កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

**ភ្នំពេញ : FM 99.5 Mhz** ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
**បាត់ដំបង : FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
**សៀមរាប: FM 102.5 Mhz** ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
**កំពង់ធំ : FM 88.5 Mhz** ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
**កំពង់ចាម : FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
**ក្រុងព្រះសីហនុ : FM 100.5 Mhz** ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
**កំពត : FM 93.25 Mhz** ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

June-2009.qxd 5/30/2009 10:10 AM Page 2

# រូបថតសម្រាប់លេខនេះ


Photo : S. Philong

យុវជនក្រុមអ្នកសម្ដែងតែងខ្លួនជាតាបស ដើម្បីចូលរួមអបអរសាទរនៅក្នុងពិធីបុណ្យឡើងអ្នកតា "ព្រឹងភ្លែក" ដែលប្រារព្ធឡើងនៅស្រុកពញាឮ ខេត្តកណ្ដាល។ ពិធីបុណ្យនេះធ្វើឡើងក្នុងគោលបំណងដើម្បីបន់ស្រន់ឱ្យអ្នកភូមិបានសេចក្ដីសុខ និងធ្វើកសិកម្មប្រមូលផលបានច្រើននៅក្នុងឆ្នាំថ្មី។ **(ឆ្វេង)**

ការប្រណាំងសេះរៀបចំឡើងនៅក្នុងឱកាសបុណ្យឡើងអ្នកតា "ព្រឹងភ្លែក" ដែលដែលជាប្រពៃណីមានតាំងតែពីបរមបុរាណមកសម្រាប់ប្រជាជននៅស្រុកពញាឮ ខេត្តកណ្ដាល។ **(ក្រោម)**


Photo : S. Philong


Photo : S. Philong

កុមារពរប្អូនសុំទាននៅតាមដងផ្លូវមួយក្នុងរាជធានីភ្នំពេញដើម្បីចិញ្ចឹមជីវិត។ តើមានស្ថាប័នណាអាចដោះបញ្ហាក្រីក្រវេទនារបស់ពួកគេបាន? **(ឆ្វេង)**


Photo : S. Philong

ឯកឧត្តមកែប ជុតិមា អភិបាលក្រុងភ្នំពេញធ្វើពិធីបួងសួង មុននឹងស្ពានព្រះមុនីវង្សថ្មីត្រូវបានដាក់សម្ពោធឱ្យប្រើប្រាស់កាលពីថ្ងៃទី២៧ ឧសភា។ **(ក្រោម)**

ស្ពានមុនីវង្សថ្មីដែលនៅខាងត្បូងស្ពានមុនីវង្សចាស់ និងឆ្លងទន្លេបាសាក់ តភ្ជាប់រវាងរាជធានីភ្នំពេញ និងផ្លូវជាតិលេខមួយ ត្រូវបានសាងសង់រួចរាល់ជាស្ថាពរកាលពីដើមខែឧសភា **(ឆ្វេង)**


Photo : S. Philong



# វិចារណកថា

## ព្រះសហគមន៍បង្ហាញ ធម៌មេត្តានៃព្រះជាម្ចាស់


Photo : P. Samphy

**លោកប៉ូលរឿង ឆត្រឆ័យ អ្នកសម្របសម្រួលមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)**

បងប្អូនជាទីស្រឡាញ់ ! ប្រជាជនយើងមួយចំនួន កំពុងតែរស់នៅដោយស្រួល ។ ខ្លះរស់នៅលើទីលំនៅដ្ឋានថ្មី ដោយសារតែគម្រោងអភិវឌ្ឍន៍ផ្សេងៗ ។ តែមានប្រជាជនមួយចំនួនទៀតដែលកំពុងរស់នៅយ៉ាងពិបាក ព្រោះគ្មានផ្ទះសំបែងដោយសារមករស់នៅក្នុងកន្លែងខុសច្បាប់ និងមិនច្បាស់លាស់ រហូតដល់ម្ចាស់កន្លែងបានត្រឡប់មកយកវិញ ឬបើសិនជាដីរដ្ឋក៏ត្រូវតែចេញទៅតាមគម្រោងរបស់រាជរដ្ឋាភិបាល ។

តើប្រជាជនដែលត្រូវចាកចេញពីទីកន្លែងកំពុងអភិវឌ្ឍន៍នោះត្រូវទៅនៅឯណា? តើរដ្ឋាភិបាលដោះស្រាយបញ្ហារបស់ពួកគាត់យ៉ាងណា? តើវាមានផលប៉ះពាល់នៅលំនៅដ្ឋានថ្មីយ៉ាងណាខ្លះ ? សូមបងប្អូនតាមដាននៅក្នុងអ្នកនាំសារនេះ ។

ពិតជាពិបាកមែន នៅពេលផ្លាស់ប្តូរផ្ទះម្តងៗ អាជ្ញាធរត្រូវខិតខំជួយសម្រួលបញ្ហាទាំងអស់ឱ្យប្រជាជន ។ ប៉ុន្តែបងប្អូនក្រីក្រខ្លះខ្វះលទ្ធភាពការយល់ដឹងអំពីតម្លៃនៃការរស់នៅយ៉ាងថ្លៃថ្នូរ បានជានាំឱ្យការរស់នៅទីកន្លែងថ្មី ខ្វះសណ្តាប់ធ្នាប់ ឬក៏លក់ដីដែលរដ្ឋចែកឱ្យនោះទៅវិញ ។ ទោះបីជារដ្ឋាភិបាលខិតខំយ៉ាងណា បើសិនខ្វះការសហការពីបងប្អូន ក៏វាមិនអាចដោះស្រាយបញ្ហាទាំងអស់នោះបានដែរ ។

ព្រះសហគមន៍កាតូលិកបានយកចិត្តទុកដាក់អ្នកអត់ទីពឹង និងមិនទទួលភាពយុត្តិធម៌នៅក្នុងសង្គម ។ ព្រះសហគមន៍យើងក៏បង្ហាញធម៌មេត្តារបស់ព្រះជាម្ចាស់ តាមការជួយសង្គ្រោះខាងសង្គមដែរ ។ យើងមានគណៈកម្មការសង្គហៈ តាមព្រះសហ-គមន៍ មានអង្គការការីតាស (Caritas) និងអង្គការសាសនាជាច្រើនដែរ ដើម្បីជួយជនក្រីក្រកំសត់ទាំងអស់នោះ ។ ដូច្នេះសូមបងប្អូនយកចិត្តទុកដាក់ចំពោះបងប្អូនដែលខ្វះខាតដោយសារបញ្ហាសង្គម ជាពិសេសចំពោះបងប្អូនដែលត្រូវផ្លាស់ទៅទីលំនៅថ្មីដែលស្ថិតនៅតាមជាយក្រុង ។

ព្រះយេស៊ូមានព្រះបន្ទូល "គ្រប់ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើទាំងនោះដាក់អ្នកតូចតាចជាងគេបំផុតម្នាក់ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះយើងដែរ ។" (ម៉ាថាយ ២៥:៤០)

**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
ក្រុមប្រឹក្សាភិបាល : លោកអេមីល ដេតម្ប ។
អ្នកសម្របសម្រួល : លោកប៉ូលរឿង ឆត្រឆ័យ ។ ប្រធាន : លោកលី សុវណ្ណា ។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងទទួលថតចម្លង CD VCD និង DVD គ្រប់ប្រភេទ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ ទូរស័ព្ទ : ០២៣ ៣៧៧ ៩៦០។ **សូមអរគុណ!**

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ានូអែល {សម្លេងពីព្រះសហគមន៍កាតូលិក} ខែមិថុនា

-បុណ្យលើកតម្កើងព្រះត្រៃឯក (០៧ មិថុនា) : លោកបូជាចារ្យ ប៊្រុយណូ កូសម៉ី មកពីក្រុមសាសនាទូតនៃទីក្រុងប៉ារីស

-បុណ្យលើកតម្កើងព្រះកាយ និងព្រះលោហិត (១៤ មិថុនា) : លោកអភិបាល អន់តូនីសាមី ស៊ូសែរាជ អភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម

-ថ្ងៃអាទិត្យទី១២ រដូវធម្មតា (២១ មិថុនា) : លោកបូជាចារ្យហ្វ្រង់កូ ឡេញ៉ានី មកពីក្រុមគ្រឹះស្ថានរបស់សម្តេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME)

-ថ្ងៃអាទិត្យទី១៣ រដូវធម្មតា (២៨ មិថុនា) : លោកបូជាចារ្យ លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

### កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក" (FM 99.5 Mhz) ប្រចាំខែមិថុនា

ថ្ងៃទី១ មិថុនា : ស្នេហ៍មិនស្មោះ ថ្ងៃទី២ មិថុនា : ភក្តីភាពស្នេហ៍ ថ្ងៃទី៨ មិថុនា : ដំណោះស្រាយពេលជួបស្នេហ៍មិនស្មោះ។ ថ្ងៃទី៩ មិថុនា : ទំនុកចិត្ត។ ថ្ងៃទី១៥ មិថុនា : ខ្ញុំអាចធ្វើបាន ! ថ្ងៃទី១៦ មិថុនា : គិតសិនសឹមគួរ។ ថ្ងៃទី២២ មិថុនា : ស្តាប់គ្នាទៅវិញទៅមក។ ថ្ងៃទី២៣ មិថុនា : ត្រឹមតែក្រសែភ្នែក។ ថ្ងៃទី២៩ មិថុនា : ព្យាយាមគង់បានសម្រេច។ ថ្ងៃទី៣០ មិថុនា : លើកដៃគងថ្វាស។ ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិន ដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។

**សូមកុំភ្លេចស្តាប់!**

June-2009.qxd 5/30/2009 10:10 AM Page 4

# សេដ្ឋកិច្ច

## ទេសចរណ៍ខ្មែររងគ្រោះដោយវិបត្តិសេដ្ឋកិច្ច

**ខាន់ ភីរម្យ**


Photo : S. Philong

អ្នកជំនាញវិស័យទេសចរណ៍បានអះអាងថា វិបត្តិសេដ្ឋកិច្ចពិភពលោកនៅតែគំរាមកំហែងមកដល់វិស័យទេសចរណ៍របស់កម្ពុជា ។

ការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរណ៍ធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ត្រូវបានគេមើលឃើញតាំងតែពីពាក់កណ្ដាលឆ្នាំ២០០៨ មកម្ល៉េះ ពោលគឺក្រោយពេលដែលវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុ បានរីករាលដាលនៅទូទាំងពិភពលោក ។

នៅ៦ខែ ដើមឆ្នាំ២០០៨ ចំនួនភ្ញៀវទេសចរណ៍បរទេសមកកម្ពុជាទទួលបានកំណើន ១២,៦% ។ ប៉ុន្តែវាបានធ្លាក់ចុះចំនួន ១,២%វិញ នារយៈពេល ៦ខែចុងឆ្នាំ ។ ហើយមកដល់បីខែនៃដើមឆ្នាំនេះទៀត វាធ្លាក់ចុះបន្តចំនួន ៣,៤% ទៀត ។ ហើយមកដល់ខែឧសភា ឆ្នាំ២០០៩ នេះ វិបត្តិហិរញ្ញវត្ថុនៅ មិនទាន់បានស្ដារឡើងវិញនៅឡើយទេ ។ ហើយអ្វីដែលធ្ងន់ធ្ងរជាងនេះទៀតនោះ គឺការលេចឡើងនៃជំងឺគ្រុនផ្ដាសាយម៉ិកស៊ិក ដែលត្រូវបានគេអះអាងថា វាក៏អាចជាឧបសគ្គមួយទៀត ដែលអាចប៉ះពាល់ដល់វិស័យទេសចរណ៍របស់កម្ពុជាផងដែរ ។

លោកហូ វណ្ណី ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា បានមានប្រសាសន៍ថា ផលប៉ះពាល់ដោយសារវិបត្តិហិរញ្ញវត្ថុពិភពលោកមកលើវិស័យទេសចរណ៍ គឺជារឿងដែលមិនអាចប្រកែកបាន ។ តែផលប៉ះពាល់ពីគ្រុនផ្ដាសសាយម៉ិកស៊ិក យើងរង់ចាំមើលសិន ។ លោកបញ្ជាក់ទៀតថា : "ការធ្លាក់ចុះកាលពីបីខែមុន គឺដោយសារវិបត្តិហិរញ្ញវត្ថុ ។ តែចំពោះគ្រុនផ្ដាសាយម៉ិកស៊ិក យើងអត់ទាន់ដឹង" ។

ផ្អែកទៅតាមបទពិសោធន៍របស់លោកវណ្ណី បានឱ្យដឹងថា វិស័យទេសចរណ៍កម្ពុជា អាចបន្តជួបបញ្ហាដោយសារតែវិបត្តិហិរញ្ញវត្ថុ ប៉ុន្តែមិនមែនដោយសារការរីករាលដាលជំងឺគ្រុនផ្ដាសសាយម៉ិកស៊ិកទេ ព្រោះមកដល់ពេលនេះ កម្ពុជានៅមិនទាន់មានករណីនេះនៅឡើយ ហើយវិស័យទេសចរណ៍របស់យើងនៅតែដំណើរការដដែល ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងឃើញថា រដ្ឋាភិបាលក៏កំពុងតែប្រឹងប្រែងដែរក្នុងការចាត់វិធាន ដើម្បីទប់ទល់នឹងការរីករាលជំងឺនេះ ។ លោកវណ្ណីបញ្ជាក់ថា: "យើងកំពុងចាំមើល តែពេលនេះយើងនៅរកស៊ីធម្មតា" ។

### ទីផ្សារទេសចរណ៍កម្ពុជា

ក្រសួងទេសចរណ៍ បានឱ្យដឹងថា ទីផ្សារទេសចរណ៍របស់កម្ពុជា គឺមកពី ៨តំបន់ធំៗ ហើយតំបន់ដែលមានសក្ដានុពលច្រើនជាងគេ គឺអាស៊ីខាងកើតដែលមានប្រទេសចិន ហុងកុង ជប៉ុន និងកូរ៉េជាដើម។

ស្ថិតិកាលពីឆ្នាំ២០០៨ បានឱ្យដឹងថា នៅក្នុងចំណោមភ្ញៀវទេសចរណ៍បរទេសទាំងអស់ចំនួន ២១២៥៤៦៥នាក់ ភ្ញៀវទេសចរណ៍ដែលមកពីអាស៊ីខាងកើត មានចំនួន ៦៤៦៤៣២នាក់ បន្ទាប់មកគឺអាស៊ាន មានចំនួន ៥៥២៤៦១នាក់ និងអឺរ៉ុបមានចំនួន ៤៥៧៤៧១នាក់។

ក្រៅពីនេះ មានភ្ញៀវមកពីអាស៊ីខាងត្បូង អាម៉េរិក អាហ្វ្រិក និងតំបន់មជ្ឈិមបូព៌ា។ ប៉ុន្តែបើនិយាយអំពីការលេចធ្លោនោះ គឺភ្ញៀវទេសចរណ៍វៀតណាម។ ស្ថិតិបានបង្ហាញថា បីខែដើមឆ្នាំ២០០៩ ភ្ញៀវទេសចរណ៍វៀតណាម មកទស្សនាកម្ពុជា បានកើនឡើងដល់ទៅ ៤៩%ឯណោះ ដែលក្លាយជាភ្ញៀវទេសចរណ៍នាំមុខគេនៅកម្ពុជា។

# សុខភាព

## រោគសញ្ញាផ្ដាសាយម៉ិកស៊ិក មានក្ដៅខ្លួនខ្លាំង ឈឺក ឈឺក្បាល...

**ស្មើកម្ពុជា លេខ ៤៨៨៤**



Photo : DR

ពិភពលោកកំពុងព្រួយបារម្ភយ៉ាងខ្លាំងចំពោះការផ្ទុះឡើងនូវជំងឺផ្ដាសាយម៉ិកស៊ិក ដែលពីដំបូងហៅថាផ្ដាសាយជ្រូក ។ ផ្ដាសាយនេះ គឺជាជំងឺផ្លូវដង្ហើមដែលបង្កឡើងដោយវីរុសផ្ដាសាយ**A/H1N1** ហើយគឺអាចឆ្លងពីមនុស្សទៅមនុស្ស ។ ការបរិភោគសាច់ជ្រូកចម្អិនត្រឹមត្រូវមិនបណ្ដាលឱ្យឆ្លងទេ ។

រោគសញ្ញានៃផ្ដាសាយម៉ិកស៊ិកដូចគ្នានឹងផ្ដាសាយទូទៅដែរមានដូចជាគ្រុនក្ដៅ ក្អក ឈឺក ឈឺខ្លួន ឈឺក្បាល រងា ហៀរសម្បោរ ឬអស់កម្លាំង... ។ មនុស្សមួយចំនួនទៀតត្រូវបានគេរាយការណ៍មកថា មានរាគរូស និងចង់ក្អួត ។ រោគសញ្ញាទាំងនោះអាចបង្កឡើងដោយលក្ខខណ្ឌជាច្រើនទៀតមានន័យថា អ្នកនិងវេជ្ជបណ្ឌិត ក៏មិនអាចដឹងគ្រាន់តែផ្អែកលើរោគសញ្ញាដូច្នេះឡើយ ។ អ្នកកើតជំងឺផ្ដាសាយម៉ិកស៊ិក ទាល់តែពិនិត្យក្នុងបន្ទប់ពិសោធន៍ទើបដឹង ។

លោកអ្នកអាចទទួលមេរោគ ដោយផ្ទាល់ពីអ្នកជំងឺ តាមរយៈប៉ះពាល់វត្ថុដែលអ្នកជំងឺប្រើប្រាស់ បន្ទាប់មកលោកអ្នកយកមកប៉ះភ្នែកច្រមុះឬមាត់ ។ វីរុសផ្ដាសាយម៉ិកស៊ិកក៏អាចឆ្លងតាមអាកាស ប្រសិនបើអ្នកក្អក ឬកណ្ដាស់ ដោយមិនខ្ទប់មាត់ច្រមុះ ព្រោះវាបញ្ជូនមេរោគទៅក្នុងអាកាស ។

វីរុសផ្ដាសាយម៉ិកស៊ិកថ្មីនេះអាចព្យាបាលដោយឆ្នាំ **Tamiflu** ។ ករណីនៅអាម៉េរិក មន្ទីរពិសោធន៍ បានអះអាងថា អ្នកជំងឺផ្ដាសាយម៉ិកស៊ិកខ្លះ បានជាសះស្បើយដោយមិនបាច់ព្យាបាល ។

ដើម្បីបង្ការលោកអ្នកត្រូវលាងដៃជាប្រចាំដោយសាប៊ូ និងទឹក ជាពិសេសក្រោយពីក្អក ឬកណ្ដាស់ ។ ម្យ៉ាងទៀតអ្នកអាចប្រើសម្ភារៈ ដោយសម្អាត ឱ្យស្អាត ឬសម្អាតដៃដោយប្រើអាកុល ។ សូមចៀសវាងកុំទៅជិតអ្នកដែលឈឺ ។ ដៃរបស់អ្នកដែលជាប់មេរោគ សូមកុំយកទៅប៉ះមាត់ច្រមុះ ឬភ្នែក ។



# យុវវ័យ



Photo : S. Philong

## អ្នកជំនាញ : "យុវជនមិនមែនជាឧក្រិដ្ឋជន"

**ខាន់ ភីរម្យ**

ប្រធាននៃមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍន៍ និងសន្តិភាពបានអះអាងថា សម័យនេះអំពើហិង្សា ពិតជាកើតមាននៅក្នុងចំណោមយុវជន ជាច្រើនមែន ។ ប៉ុន្តែជាទូទៅ ពួកគេគ្រាន់តែជាជនរងគ្រោះតែប៉ុណ្ណោះ ។

លោកយ៉ង់ គីមអេង ប្រធានមជ្ឈមណ្ឌលនេះ មានប្រសាសន៍ថា អំពើហិង្សា និងវាយតប់គ្នាភាគច្រើន គឺបង្កឡើងដោយយុវជន ។ ប៉ុន្តែពួកគេដាច់ខាតមិនមែនជាជនល្មើសឡើយ ។ មកដល់ពេលនេះការប្រើប្រាស់អំពើហិង្សានៅក្នុងការដោះស្រាយបញ្ហា ពិតជាកើតមាន ក្នុងចំណោមយុវជនច្រើនមែន ។ ប៉ុន្តែគ្រប់ភាគីទំនាស់ទាំងអស់ក្នុងអំពើហិង្សា ឬជម្លោះ ពួកគេមិនមែនជាអ្នកបង្កហេតុ ឬជាជនល្មើសទេ ។ ពួកគេជាជនរងគ្រោះទាំងអស់គ្នា ។ ចំណែកអ្នកបង្កហេតុ ឬជាជនល្មើសនោះ គឺជាសង្គមទេ ។

ពាក់ព័ន្ធជាមួយនឹងបញ្ហានេះ លោកគីមអេង បានទទួលស្គាល់ថា អំពើហិង្សាភាគច្រើន គឺយុវជនជាអ្នកបង្កហេតុមែន ។ ប៉ុន្តែឫសគល់របស់អំពើហិង្សាដែលស៊ីជម្រៅនោះ គឺដោយសារតែការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន កង្វះខាតការអប់រំ និងការសប្បាយភ្លើតភ្លើនជាដើម ។ លោកក៏បានឱ្យដឹងថា យុវជនគាត់វាយគ្នាពិតជាមានកំហុស ។ តែអ្នកដែលរឹតតែខុសនោះ គឺសង្គម ពីព្រោះគាត់វាយគ្នានេះដោយសារតែស្រវឹង ចុះនរណាដែលធ្វើឱ្យគាត់ស្រវឹងគឺមិនសង្គមចូលរួម ។ លោកបានបញ្ជាក់ថា : "បើសង្គមអត់នាំចូលស្រា អត់បង្កឱ្យយុវជនស្គុកស្គាញ ហើយផ្ដល់សេវាឱ្យគាត់ បានគ្រប់គ្រាន់នោះ តើគាត់នៅសុខៗ អាចវាយគ្នាបានទេ?" ។

អ្វីដែលលោកគីមអេងបានលើកឡើងមកនេះ គឺវាស្របគ្នានឹងអ្វីដែលយុវជនពីររូបដែលធ្លាប់ប្រឡូកនឹងអំពើវាយតប់គ្នាបានលើកឡើង ។ យុវជនទាំងពីររូបនេះ បានឱ្យដឹងថា ភាគច្រើនអំពើវាយតប់គ្នាច្រើនកើតមានឡើង នៅពេលផឹកស៊ី និងពេលពួកគេស្វែងរកសេវាកំសាន្តនានា ។

យុវជនមួយរូប អាយុ ២៣ឆ្នាំ មានទីលំនៅនៅក្នុងភូមិព្រែកស្បូវ ស្រុកស្ទឹងសែនខេត្តកំពង់ធំ ថ្លែងថា រូបគេតែងតែបានជួបប្រទះនឹង អំពើវាយតប់គ្នា គឺនៅពេលពួកគេដើរលេងឆ្លងភូមិ និងដូចជាពេលគេរៀបចំពិធីរាំវង់ជាដើមដោយម្ដងមានប្រជុំគ្នាជាក្រុមៗ ដែលមានគ្នារហូតដល់២០ ទៅ៣០នាក់ ក៏មាន ។ យុវជននោះបានបញ្ជាក់ថា : "គ្នាច្រើនអាងដល់ពេលរាំ គេជាន់ជើង ឬមើលមុខ អត់សុំទោស យើងដាក់គ្នាហើយ" ។

យុវជនមួយរូបទៀតមានអាយុ ២៤ឆ្នាំ នៅក្នុងភូមិដដែល ហើយដែលធ្លាប់ចូលរួមការវាយតប់គ្នាតាំងតែពីពេលដែលគេ អាយុ ១៧ឆ្នាំនោះ បានឱ្យដឹងថា រូបគេនឹងក្រុមយុវជននៅក្នុងភូមិច្រើនវាយគ្នា នៅពេលដើរលេងតាមវត្ត ឬពិធីផ្សេងៗ ដែលគេរៀបចំឡើងដើម្បីការសប្បាយ ហើយជួនកាល គេវាយតប់គ្នាឯងនៅក្នុងភូមិជាមួយគ្នាក៏មាន ជាពិសេសគឺនៅពេលស្រវឹង ។ យុវជនរូបនោះបញ្ជាក់ថា : "តែស្រវឹងមិនចាំបាច់គ្នាឯងគ្នាគេទេ តែគងសំដីគ្នា ទោះបីជាគ្នាឯង ក៏ព្រលះគ្នាដែរ" ។

ដើម្បីដោះស្រាយបញ្ហាវាយតប់គ្នានេះ លោកគីមអេងផ្ដល់អនុសាសន៍ថា សង្គមអាចនឹងដោះស្រាយ ឬលុប បំបាត់បញ្ហានេះបាន ប្រសិនមានការពង្រឹងគុណភាពអប់រំ ពង្រឹងទំនាក់ទំនងរវាងសាលារៀន និងអាណាព្យាបាល ពង្រឹងច្បាប់ និងការអនុវត្តន៍ ។ ហើយនៅក្នុងនោះសហគមន៍គួររួមគ្នាបង្កើតមជ្ឈមណ្ឌលកំសាន្តនានាសម្រាប់យុវជន ។ លោកក៏បានបញ្ជាក់ថា : "តែពួកគេលែងផឹកស្រា លែងអផ្សុក និងរវល់ ខ្ញុំគិតថា ពួកគេច្បាស់ជាលែងវ៉ៃគ្នា" ។

## កសិកម្ម

# តើការប្រើជីគីមីល្អ ឬជីធម្មជាតិល្អ ?

**ជាត សំភី**


Photo : P. Samphy
ជីគីមីមានច្រើនប្រភេទ ដែលត្រូវប្រើរូបមន្តខុសៗគ្នា

លោកហង់ ប៊ុនណារ៉ា ប្រធានដេប៉ាតឺម៉ង់សាកវប្បកម្មសាលាកសិកម្មព្រែកលាប មានប្រសាសន៍ថា: បើយើងនិយាយពីជីគីមី និងជីធម្មជាតិ ទាំងពីរនេះ សុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិរាងខ្លួន។ ជីគីមីមាន ប្រតិកម្មលឿន ដែលធ្វើឱ្យដំណាំឃើញល្អភ្លាមៗ។ តែគុណវិបត្តិរបស់វា គឺការប្រើប្រាស់ត្រូវទាមទារឱ្យមានបទដ្ឋាន និងរូបមន្តច្បាស់លាស់ដូចជាត្រូវប្រើប្រាស់ទំហំប៉ុន្មានគីឡូ សម្រាប់ដីប្រភេទណា ប្រើប្រាស់លើដំណាំអ្វី ឬក៏ប្រើប្រាស់នៅពេលណាពេលដំណាំលូតលាស់-ល-។ ដូច្នេះកសិករមានការលំបាកក្នុងការចាប់យកនូវបច្ចេកទេស ឱ្យបានច្បាស់លាស់ ពីព្រោះបទដ្ឋាន និងរូបមន្ត ជាក់លាក់គឺមានតែផ្សព្វផ្សាយចេញពីមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្ម និងអ្នកជំនាញដែលពួកគេធ្វើការនៅតំបន់ខ្លះៗប៉ុណ្ណោះ។ ផ្ទុយទៅវិញបើប្រើប្រាស់ជីគីមីខុសបទដ្ឋាន វាមិនត្រឹមតែមិនបង្កើនទិន្នផលទេ គឺថែមទាំងជំរុញឱ្យទិន្នផលធ្លាក់ចុះ ហើយដីក៏ខូចទៀត។ ចំណែកជីធម្មជាតិ ដូចជាជីកំប៉ុស្ដ ឬក៏ជីលាមកសត្វជាដើម។ វាមានប្រតិកម្មយឺតៗ។ កសិករមិនងាយឃើញដំណាំល្អភ្លាមនោះទេ ទាល់តែចាំមួយរយៈ។ ប៉ុន្តែជីនេះមិនធ្វើឱ្យខូចដី។ លើសពីនេះជីនេះ អាចធ្វើឱ្យដីដែលខូចហិរហើយ ប្រែមកភាពដើមទៀតផង។ លោកហង់ ដារ៉ា បានគូសបញ្ជាក់ថា ការប្រើប្រាស់ជីគីមីកសិកម្មលើសកំណត់ ឬក៏មិនត្រឹមត្រូវតាមបច្ចេកទេសអាចធ្វើឱ្យដីខូចហិរ។ ប៉ុន្តែយើងក៏អាចធ្វើការកែប្រែដីដែលខូចហិរនេះបាន។ កសិករអាចប្ដូរមកប្រើជីធម្មជាតិទៅលើដីដែលខូចនោះ។ ក្នុងវិធីម្យ៉ាងទៀត កសិករអាចដាំដំណាំគម្របលើដី ដោយដាំក្រុមពពួកសណ្ដែក ដូចជាសណ្ដែកបាយ សណ្ដែកសៀង សណ្ដែកគុយ... ព្រោះសណ្ដែកអាចមានលទ្ធភាពធ្វើការចាប់យកអាសូតពីបរិយាកាសមកក្នុងដីដែលធ្វើឱ្យដីមានជីជាតិឡើងវិញ។

លោកហង់ ប៊ុនណារ៉ា ក៏បានផ្ដាំផ្ញើថា តាមយោបល់លោកការប្រើប្រាស់ ជីធម្មជាតិដូចជាកំប៉ុស្ដ គឺមានភាពប្រសើរជាង ព្រោះកសិករមិនចាំបាច់មានបទដ្ឋានប្រើប្រាស់ ពោលគឺប្រើរឹតតែច្រើន កាន់តែល្អ។ ហើយការប្រើប្រាស់នេះ ក៏វាមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថានផងដែរ។ ម្យ៉ាងវត្ថុធាតុដើមធ្វើជីធម្មជាតិ ឬជីកំប៉ុស្ដ គេអាចរកបានដោយងាយស្រួលនៅក្នុងមូលដ្ឋាន។ ម្យ៉ាងទៀត កសិករគួរធ្វើប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍នៃធម្មជាតិផងដែរ ដើម្បីកាន់តែបង្កើនទិន្នផលជាមួយនិងនិរន្តរភាព។

## បរិស្ថាន

# រុក្ខជាតិមានតម្លៃ

គ្រូឱសថបុរាណមួយរូប បានអះអាងថា រាល់រុក្ខជាតិទាំងអស់សុទ្ធតែមានតម្លៃផ្នែកឱសថសម្រាប់សង្គ្រោះជីវិតមនុស្ស។


Photo : DR
រុក្ខជាតិនៅក្នុងស្រុកសុទ្ធតែមានតម្លៃខាងឱសថ

លោកស្រី ឡុង ស៊ីណាង គ្រូឱសថបុរាណ យីហោ "ខ្មែរអង្គរវត្ត"មានប្រសាសន៍ថា រុក្ខជាតិទាំងអស់ដែលដុះនៅលើលោក ពិសេស នៅប្រទេសកម្ពុជា គឺសុទ្ធតែអាចមានប្រយោជន៍ដល់មនុស្សទាំងអស់ បើសិក្សាស្រាវជ្រាវវាឱ្យបានច្បាស់លាស់នោះ។ សព្វថ្ងៃនេះជាមួយនឹងរុក្ខជាតិប្រមាណជា ២៤មុខ លោកស្រីឡុង ស៊ីណាង អាចធ្វើឱសថបុរាណខ្មែរលើប្រព័ន្ធរំលាយអាហារ ក្រពះ និងពោះវៀន ជាដើម។ លោកស្រីប្រាប់ថា ថ្នាំរបស់លោកស្រី មានផ្សំតាំងតែពីចេកខ្ចី ប៉េងប៉ោះ ស្រោមស្មៅក្រវាញ ជ្រូក ស្មៅប្រម៉ាត់មនុស្ស ជាដើម។
ប្រភេទរុក្ខជាតិទាំងអស់នោះ គឺមានដុះនៅពាសពេញប្រទេសកម្ពុជា។ ប៉ុន្តែលោកស្រី មិនបានដើរបេះវាដោយផ្ទាល់នោះទេ គឺលោកស្រីបានទិញពីអ្នកផ្គត់ផ្គង់របស់លោកស្រីដោយរុក្ខជាតិប្រភេទខ្លះលោកស្រីបានទិញពីគេ នៅក្នុងមួយគីឡូក្រោម ១0000រៀលក៏មាន។ វាក៏ថ្លៃគួរសមដែរ ខណៈដែលកាលប៉ុន្មានឆ្នាំមុនវាថោកណាស់។ ការឡើងថ្លៃដូច្នេះ គឺដោយសាររុក្ខជាតិទាំងនេះ មួយចំនួនចេះតែខ្សត់ៗ។ ដូច្នេះលោកស្រីបានអំពាវនាវ ឱ្យមានការអភិរក្សចំពោះរុក្ខជាតិទាំងនោះផង។
លោកស្រីស៊ីណាង ក៏បញ្ជាក់ថា: "សំណាងហើយដែលរុក្ខជាតិខ្ញុំត្រូវការ គឺវាសម្បូរ ទីណាក៏មានដុះ តែបើថ្នាំព្យាបាលជំងឺខ្លះរបស់គ្រូផ្សេងៗ ចំរុក្ខជាតិកម្រ គឺថ្លៃជាងថ្នាំពេទ្យរាប់សិបដងក៏មាន"។

**ខាន់ ភិរម្យ**



## អង្គការ

# HIB ខិតខំផ្សព្វផ្សាយការពាក់មួកដើម្បីអាយុជីវិត

**ជាត សំភី**


Photo : L. Samphors
ការពាក់មួកសុវត្ថិភាពឱ្យបាន ១០០% នៅតែជាគោលដៅចម្បងរបស់រដ្ឋាភិបាល ដើម្បីការពារអាយុជីវិតប្រជាជន

ក្នុងគោលបំណងដើម្បីកាត់បន្ថយពិការភាព របួសស្នាម និងស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ អង្គការជនពិការអន្តរជាតិប៊ែលហ្ស៊ិក ឬអេជអាយប៊ី HIB បានបង្កើតកម្មវិធី សុវត្ថិភាពផ្លូវថ្នល់។ កម្មវិធីនេះត្រូវបង្កើតឡើង ក្រោយពីមានការសិក្សាមួយដែលបង្ហាញថា មនុស្សស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍មួយចំនួនធំ គឺដោយសារតែរបួសក្បាលចំពោះអ្នកប្រើប្រាស់ម៉ូតូជាយានជំនិះ។ឈរលើមូលហេតុនេះ អេជអាយប៊ី បានបង្កើតយុទ្ធនាការបំផុសឱ្យប្រជាជនប្រើប្រាស់មួកសុវត្ថិភាព តាំងពីឆ្នាំ២០០៤ នៅទូទាំងប្រទេសដោយផ្ដោតជាដំបូងនៅភ្នំពេញ។
លោកមាស ចាន់ឌី ជាមន្ត្រីកម្មវិធីសុវត្ថិភាពចរាចរប្រចាំអេជអាយប៊ី មានប្រសាសន៍ថា យើងបានធ្វើសកម្មភាពជាច្រើន ដើម្បីលើកកម្ពស់ ការពាក់មួកទាំងការផ្សព្វផ្សាយ និងការអប់រំដល់ទីកន្លែង។ តួយ៉ាងកាលពីឆ្នាំ២០០៤ យើងមានកម្មវិធីចែកមួកជានិមិត្តរូបដល់សិស្សសាលាចំនួន ១៥០០នាក់ នៅឯពហុកីឡាដ្ឋានជាតិអូឡាំពិកក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទនរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ តពីនោះ អេជអាយប៊ីមានផលិតជាស្ពតអប់រំពីសារៈសំខាន់នៃការពាក់មួកដើម្បីផ្សព្វផ្សាយលើកញ្ចក់ទូរទស្សន៍និងវិទ្យុ។ លើសពីនេះ យើងក៏មានផ្សព្វផ្សាយរាល់ពិធីបុណ្យជាតិធំៗ មានជាអាទិ៍បុណ្យ អុំទូកជាដើម។ អេជអាយប៊ីតាំងស្តង់របស់ខ្លួន ដើម្បីនិយាយអំពីច្បាប់ចរាចរណ៍ដោយផ្ដោតជាសំខាន់លើការប្រើប្រាស់មួកសុវត្ថិភាព។ ចំណែកឯកាលពីឆ្នាំ២០០៧ ដោយមានជំនួយពីអង្គការភាពជាដៃគូដើម្បីសុវត្ថិភាពផ្លូវថ្នល់ពិភពលោក អេជអាយប៊ីក៏បានរៀបចំសិក្ខាសាលាមួយដោយអញ្ជើញគណៈកម្មការជាតិសុវត្ថិភាពចរាចរណ៍ មន្ត្រី និងក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធនានា ដើម្បីជួយបង្កើតជាផែនការយុទ្ធសាស្ត្រមួយសម្រាប់ថ្នាក់ជាតិក្នុងការលើកកម្ពស់ការពាក់មួកសុវត្ថិភាព។
លោកមាស ចាន់ឌី គូសបញ្ជាក់ដែរថា សម្រាប់ការផ្សព្វផ្សាយការពាក់មួកសុវត្ថិភាព គ្មានអ្វីជាលំបាកធ្ងន់ធ្ងរទេ ពីព្រោះវាជាការងារដែលត្រូវធ្វើ។ ប៉ុន្តែមានបញ្ហាមួយ គឺមានប្រជាជនជាច្រើន ដែលគាត់មិនទាន់អនុវត្តតាមយើងបាន១០០%។ ដូច្នេះយើងមានតែខិតខំផ្សព្វផ្សាយបន្តទៀត។

# ការពាក់មួកមានការកើនឡើង បន្ទាប់ពីការរឹតបន្តឹង

ច្បាប់ចរាចរណ៍ផ្លូវគោក បានចូលជាធរមានកាលពីថ្ងៃទី៨ កុម្ភៈ ឆ្នាំ២០០៧។ ទោះជាយ៉ាងណាការរឹតបន្តឹងលើការពាក់មួកពិតប្រាកដ ទើបតែចាប់ផ្ដើមកាលពីថ្ងៃ១ មករា ឆ្នាំ២០០៩នេះ ប៉ុណ្ណោះ។
យោងតាមការសិក្សាមួយរបស់អង្គការជនពិការអន្តរជាតិប៊ែលហ្ស៊ិកបង្ហាញថា កាលពីខែមិថុនា ឆ្នាំ២០០៨ នៅក្រុងភ្នំពេញ អ្នកបើកបរទោចក្រយាន និងអ្នករួមដំណើរផង មានចំនួនត្រឹម២៤%ប៉ុណ្ណោះ ដែលបានពាក់មួក សុវត្ថិភាព ក្នុងពេលធ្វើដំណើរ។ លុះមកដល់សប្ដាហ៍ទីមួយនៃខែកុម្ភៈ នាឆ្នាំ២០០៩ ពោលគឺរយៈពេលមួយខែក្រោយពីអនុវត្តន៍ច្បាប់ស្ដីអំពីការពាក់មួកសុវត្ថិភាព អត្រាអ្នកប្រើប្រាស់ក្នុងចំណោមអ្នកបើកម៉ូតូ បានកើនដល់ ៥៦%។ ឆ្លងតាមរយៈស្ថិតិនេះ អត្រានៃការពាក់មួកពុំអាចកើនឡើងដល់ ១០០% ភ្លាមនោះទេ។ លោកមាស ចាន់ឌី មានប្រសាសន៍ថា កត្តាដែលជំរុញឱ្យប្រជាជនសម្រេចចិត្តមិនពាក់មួក គឺមានច្រើនដូចជា គេមិនមានទម្លាប់។ វាគឺជាបន្ទុកបន្ថែមដូចជាត្រូវផ្ញើ និងពិបាកទុកដាក់។ ហើយចំពោះយុវជន មួកអាចបិទសម្រស់ផ្ទៃមុខ និងសក់របស់គេជាដើម។ ប៉ុន្តែលោកមាស ចាន់ឌី ពន្យល់ថា មួកចាំបាច់ សម្រាប់ការពារអាយុជីវិត គេត្រូវតែពាក់វា ហើយបើពាក់បានមួយរយៈ វានឹងទម្លាប់ហើយ។


Photo : S. Philong

កាលពីថ្ងៃទី១៩ ឧសភា សម្ដេចនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា អាជ្ញាធរពាក់ព័ន្ធត្រូវតែរៀបចំបង្កើតច្បាប់ដោយតម្រូវឱ្យឃាត់ទោចក្រយានដែលម្ចាស់មិនព្រមពាក់មួកសុវត្ថិភាពទុកជាបណ្ដោះអាសន្ន។ លុះត្រាតែម្ចាស់នោះទិញមួកមកពាក់ ទើបប្រគល់ទោចក្រយាននោះត្រឡប់ទៅវិញ។

June-2009.qxd 5/30/2009 10:11 AM Page 8



## អង្គការសិទ្ធិមនុស្សថ្កោលទោសគណបក្សប្រឆាំង

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថ្កោលទោសគណបក្សប្រឆាំងអំពីបញ្ហាគំរាមសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងពេលចូលរួមបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្តក្រុង ស្រុកខណ្ឌ។ តាមរយៈសេចក្តីថ្លែងការណ៍មួយកាលពីចុង សប្តាហ៍ទីបីនៃខែឧសភា កន្លងទៅនេះ គណបក្សសមរង្ស៊ី បានត្រូវគេអះអាងថា បានជំរុញឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនស្បថ មុនពេលពួកគេត្រូវទៅចូលរួមបោះឆ្នោតអសកលមួយកាលពីថ្ងៃទី១៧ ខែឧសភា កន្លងទៅ ដែលលទ្ធផលក្រៅផ្លូវការ គឺគណបក្សប្រជាជនបានទទួលជ័យជម្នះដ៏លើសលុប។

ការថ្កោលទោសនេះ ធ្វើឡើងមួយថ្ងៃក្រោយពេលដែលប្រមុខរដ្ឋាភិបាលកម្ពុជារិះគន់សង្គមស៊ីវិលអំពីតួនាទីរបស់ពួកគេដើម្បីធានាការបោះឆ្នោតនេះឱ្យមានសេរី និងយុត្តិធម៌នោះ។

## នាយករដ្ឋមន្ត្រីថៃគ្រោងមកទស្សនកិច្ចនៅកម្ពុជាខែក្រោយ

លោកអាប៊ីស៊ីត វីចាជីវ៉ា នាយករដ្ឋមន្ត្រីនៃប្រទេសថៃគ្រោងនឹងមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជានាខែក្រោយនេះ។

កាសែតឌឹណេសិន បានអះអាងថា លោកនឹងមកដល់ប្រទេសកម្ពុជានៅក្នុងថ្ងៃទី១២ ខែមិថុនា ជាមួយនឹងគណៈប្រតិភូមួយក្រុម។

ប៉ុន្តែគេនៅមិនទាន់ដឹងអំពីរបៀបវារៈច្បាស់លាស់ ក្នុងការជួបពិភាក្សាជាមួយនិងប្រមុខរដ្ឋាភិបាលកម្ពុជានៅឡើយទេ លើកលែងតែបញ្ហានៃការប្រគល់វត្ថុបុរាណខ្មែរប្រមាណ ៧ គ្រឿង ដែលត្រូវបានគេលួចរត់ពន្ធចូល ទៅប្រទេសនេះ ហើយត្រូវអាជ្ញាធរថៃបានរឹបអូស។

នេះគឺជាលើកទីពីរហើយដែលលោកអាប៊ីស៊ីត វីចាជីវ៉ា គ្រោងមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីលោកបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីមក។ គម្រោងទស្សនកិច្ចលើកទីមួយបានត្រូវលុបចោលភ្លាមៗ ដោយសារតែបញ្ហាវិបត្តិនយោបាយនៅក្នុងប្រទេសថៃ។

## អាជ្ញាធរភូមាបើកធ្វើសវនការមេដឹកនាំគណបក្សប្រឆាំង

ក្រោយពេលដែលអាជ្ញាធរភូមាបានចោទប្រកាន់ពីបទរំលោភលើលក្ខខណ្ឌនៃការឃុំឃាំងនៅក្នុងគេហដ្ឋានដោយសារមានជនជាតិអាមេរិកមួយរូបហែលទឹកទៅដល់គេហដ្ឋានរបស់លោកស្រីនៅកណ្តាលបឹងមួយ លោកស្រីអង់សាន ស៊ូជី មេដឹកនាំគណបក្សប្រឆាំងភូមា ត្រូវបានគេនាំខ្លួនធ្វើការជំនុំជម្រះ កាលពីចុងខែឧសភា។

យោងតាមទីភ្នាក់ងារព័ត៌មានបារាំង បានរាយការណ៍ឱ្យដឹងថា លោកស្រីត្រូវបានអាជ្ញាធរ នាំចេញពីគេហដ្ឋានទៅដាក់នៅក្នុងពន្ធនាគារអ៊ីនសេន។

លោកស្រីត្រូវប្រឈមមុខនឹងការកាត់ទោសដាក់គុក ចំនួន៥ឆ្នាំ តាមរយៈបទចោទប្រកាន់ខាងលើ ប៉ុន្តែប្រសិនបើលោកស្រីត្រូវកាត់ទោសមែននោះ ប្រហែលនឹងមានការប្រឆាំងពីសហគមន៍អន្តរជាតិយ៉ាងច្រើន។

លោកបាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិបានអះអាងថា លោកនឹងធ្វើដំណើរទៅកាន់ប្រទេសភូមា ដើម្បីជំរុញឱ្យអាជ្ញាធរភូមាដោះលែងលោកស្រីស៊ូជី ។

**ខាន់ ភីរម្យ**



Photo : DR

លោក ស្រីអង់សាន ស៊ូជី

## សម្តេចប៉ាបបំពេញទស្សនកិច្ច នៅក្រុងបេថ្លេហិម



Photo : DR

សម្តេចប៉ាបបេណេឌិចទី១៦ បានយាងធ្វើបំពេញទស្សនកិច្ចនៅក្នុងក្រុងបេថ្លេហិមទឹកដីកំណើតព្រះយេស៊ូកាល ពីថ្ងៃទី១៣ ខែឧសភា។

បើយោងតាមសហភាពព័ត៌មានកាតូលិកអាស៊ី បានឱ្យដឹងថា នៅក្នុងដំណើរទស្សនកិច្ចទៅកាន់តំបន់មជ្ឈិមបូព៌ាជាលើកទីមួយនេះ ព្រះអង្គបានស្នើសុំឱ្យបញ្ចប់ជម្លោះដែលកំពុងតែកើតមានរវាងប៉ាឡេស្ទីន និងអ៊ីស្រាអែល ហើយព្រះអង្គបានស្នើសុំឱ្យភាគីអ៊ីស្រាអែលរំលាយចោលនូវការហ៊ុមព័ទ្ធរបងទៅលើប៉ាលេស្ទីនផងដែរ ខណៈពេលដែលប្រជាជាតិទាំងពីរនេះ មានទំនាស់ដ៏ស្រួចស្រាលនឹងគ្នាអស់រយៈពេល ៦១ឆ្នាំ មកហើយនោះ។

បន្ទាប់ពីបានចូលរួមពិធីធម្មយាត្រាដែលមានអ្នកចូលរួមរាប់ពាន់នាក់មកពីគ្រប់ទ្វីប នាទីក្រុងបេថ្លេហិមហើយនោះ សម្តេចប៉ាបក៏បានជួបធ្វើសវនាការជាមួយនឹង បណ្តាមេដឹកនាំប៉ាលេស្ទីន មេដឹកនាំសាសនាជ្វីប និងមេដឹកនាំអ៊ីស្រាអែល រួមនិងមេដឹកនាំមូស្លីមផងដែរ។

សម្តេចប៉ាបបេណេឌិកទី១៦ គឺជាសម្តេចប៉ាបទីបីហើយ ដែលបានយាងមកបំពេញទស្សនកិច្ចនៅក្នុងទីក្រុងបេថ្លេហិម បន្ទាប់ពីអង្គសម្តេចប៉ាបយ៉ូហានប៉ូល ទី២ និងសម្តេចប៉ាប ប៉ូលទី៦។

## អតីតប្រធានាធិបតីកូរ៉េខាងត្បូង លោករ៉ូ មូ-ហ្យ៊ុន ធ្វើអត្តឃាត

លោករ៉ូ មូ-ហ្យ៊ុន ជាអតីតប្រធានាធិបតីកូរ៉េខាងត្បូងបានទទួលមរណភាពកាលពីថ្ងៃទី២៣ ឧសភា ដោយគេសង្ស័យថា លោកបានធ្វើអត្តឃាតក្រោយពេលដែលលោករងសម្ពាធអំពីការពាក់ព័ន្ធនឹងអំពើពុករលួយកាលពេល ដែលគាត់កាន់ដំណែង។

លោករ៉ូ បានបាត់បង់ជីវិតនៅក្នុងអាយុ ៦២ឆ្នាំ ហើយលោកគឺជាប្រធានាធិបតីប្រទេសកូរ៉េខាងត្បូងពីឆ្នាំ២០០៣-២០០៨។ នៅក្នុងពេលដែលលោកកាន់តំណែង លោកធ្លាប់បានមកធ្វើបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជាកាលពីឆ្នាំ២០០៧ផងដែរ។

លោកត្រូវបានគេរាយការណ៍ថា បានលោតទម្លាក់ខ្លួនពីលើកូនភ្នំមួយក្បែរភូមិលំនៅដ្ឋានរបស់លោកនៅភាគអាគ្នេយ៍នៃប្រទេសកូរ៉េខាងត្បូងនៅវេលាម៉ោង៦:៤០នាទីព្រឹក។ លោកផុតដង្ហើមនៅម៉ោង ៩:៣០ ព្រឹកថ្ងៃដដែល ក្នុងមន្ទីរពេទ្យជិតនោះ។

ក្រៅអំពីជាប់ពាក់ព័ន្ធនឹងអំពើពុករលួយនោះ ពេលកាន់អំណាចលោកក៏ជាមនុស្សដែលគេទទួលស្គាល់ថា គឺជាមេដឹកនាំមួយរូបដែលប៉ុនប៉ងស្វែងរកសន្តិភាពជូនឧបទ្វីបកូរ៉េ។





# អ្នកជំនាញកសិកម្ម : "កសិករដល់ពេលដាំដុះដីហើយ"

**ខាន់ ភីរម្យ**

*ដោយឃើញការធ្លាក់ភ្លៀងជាបន្តបន្ទាប់កាលពីចុងខែមេសា និងដើមខែឧសភា កន្លងទៅនេះ អ្នកនាំសារបានធ្វើការសម្ភាសន៍ជាមួយលោកបណ្ឌិតយ៉ង់ សាំងកុមារ ប្រធានមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មនៃអង្គការសេដាក លើបញ្ហាបង្កបង្កើនផលស្រូវរដូចតទៅនេះ*



Photo : L. Sovanna

**លោកបណ្ឌិតយ៉ង់ សាំងកុមារ ប្រធានមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មហៅសេដាក ជំរុញផលិតកម្មស្រូវសរីរាង្គ**

**អ្នកនាំសារ : តើកសិករអាចចាប់ផ្តើមដកស្ទូងបានហើយឬនៅ មកដល់ពេលនេះ?**

**លោកសាំងកុមារ**: ឆ្នាំនេះ យើងសង្កេតក៏ឃើញថាភ្លៀងបានចាប់ផ្តើមធ្លាក់តាំងតែពីដើមរដូវ។ ដូច្នេះវាគឺជារឿងមួយល្អសម្រាប់ការចាប់ផ្តើមរដូវដាំដុះដំណាំស្រូវរដូវវស្សា។ វាជាឱកាសល្អមួយសម្រាប់ប្រជាកសិករខ្មែរយើងត្រៀមខ្លួនសម្រាប់រដូវដាំដុះស្រូវថ្មីរបស់ពួកគាត់។

**អ្នកនាំសារ : តើកសិករត្រូវត្រៀមអ្វីខ្លះដើម្បីផលិតស្រូវដែលមានគុណភាព និងមានជីវជាតិគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ការហូបចុករបស់មនុស្ស?**

**លោកសាំងកុមារ** : ក្រោយពេលដែលមានភ្លៀងធ្លាក់ជោគជាំដូចកាលពីចុងខែ៤ និងដើមខែ៥កន្លងទៅនេះ កសិករគ្រប់រូបគួរតែចាប់ផ្តើមភ្ជួរដី ដើម្បីលុបជើងជញ្ជ្រាំង ឱ្យដីមានជីជាតិ និងធូរ។ ហើយកសិករគួរតែធ្វើដំណាំរួមផ្សំផ្សេងៗទៀតដែរ ក្រៅពីស្រូវ ដូចជាការដាំសណ្តែកដើម្បីបានផលសណ្តែកនោះផង និងក៏អាចក្លាយជាជីដ៏មានជីជាតិសម្រាប់ដំណាំស្រូវផង។ ក្រៅពីនោះកសិករត្រូវចេះជ្រើសរើសពូជឱ្យបានត្រឹមត្រូវ។

**អ្នកនាំសារ: តើមកដល់ពេលនេះ នៅក្នុងចំណោមកសិករដែលមានប្រមាណ ៨០% នៃប្រជាពលរដ្ឋទាំងអស់ តើមានប្រជាពលរដ្ឋប៉ុន្មានភាគរយដែលកំពុងតែបង្កបង្កើនផលស្រូវសរីរាង្គ?**

**លោកសាំងកុមារ** : ការបង្កបង្កើនផលស្រូវសរីរាង្គដែលគ្មានជាតិគីមី ជាប្រពៃណីរបស់ប្រជាជនខ្មែរ។ ពីដើមរៀងមក កសិករនៅក្នុងប្រទេសទាំងអស់ គឺសុទ្ធតែបង្កបង្កើនផលស្រូវសរីរាង្គ។ តែក្រោយមកពេលមកដល់ទសវត្សរ៍ទី៨០ ជាពិសេស នាក្រោយពេល ដែលជីគីមី និងថ្នាំពុលកសិកម្ម បានចូលមកកម្ពុជាតាមរយៈការរីកចម្រើននៃឧស្សាហកម្ម និងពាណិជ្ជកម្ម កសិករកម្ពុជា សឹងតែពី៧០ ទៅ៧៥% ហើយដែលគាត់ប្រើជីគីមី។ តាមស្ថិតិរបស់អង្គការសេដាកមកដល់ពេលសព្វថ្ងៃនេះ កសិករដែលគាត់នៅតែប្រកបរបរធ្វើស្រូវសរីរាង្គសុទ្ធសាធ គឺមានប្រមាណជា ៨០០០គ្រួសារតែប៉ុណ្ណោះ។ ប៉ុន្តែទោះជាយ៉ាងណា និន្នាការមករកការដាំដុះស្រូវសរីរាង្គនេះ កំពុងតែកើនឡើង។

**អ្នកនាំសារ : តើមកដល់ពេលនេះនៅទូទាំងប្រទេសកម្ពុជាមានផ្ទៃដីដាំដុះដំណាំស្រូវប៉ុន្មានដែរ? ហើយទិន្នផលស្រូវអាចមានការកើនឡើង ឬថយចុះ?**

**លោកសាំងកុមារ**: ផ្ទៃដីសម្រាប់ធ្វើស្រែនៅកម្ពុជានៅពេលនេះ មានចំនួនប្រមាណ ២,៥លាន ហិចតា នៅក្នុងនោះមានពី២លានហិចតា ដែលជាវាលស្រែវស្សា ហើយ៥០០០០ហិចតាជាវាលស្រែប្រាំង។ ហើយសម្រាប់ការធ្វើស្រូវនៅរដូវវស្សាឆ្នាំនេះ បើផ្អែកលើអាកាសធាតុ និងការយល់ដឹងបច្ចេកទេសរបស់កសិករទិន្នផលស្រូវនៅកម្ពុជាឆ្នាំក្រោយអាចនឹងកើនឡើង"។ ដំណាំស្រូវនៅកម្ពុជាឆ្នាំក្រោយអាចនឹងទទួលបានទិន្នផលលើសឆ្នាំនេះ ដោយសារមានភាពអំណោយផលច្រើនដែលផ្តល់ឱ្យទាំងកត្តាធម្មជាតិ និងកត្តាមនុស្ស។

### ទិន្នផលស្រូវឆ្នាំនេះអាចនឹងកើនឡើង

**លោកបណ្ឌិតយ៉ង់ សាំងកុមារ ប្រធានមជ្ឈ-មណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្ម មានប្រសាសន៍ថា ប្រជាកសិករខ្មែរកាន់តែមានការយល់ដឹងអំពីបច្ចេកទេសកសិកម្ម ពិសេសការដាំដុះដំណាំស្រូវ។ ចំណែកការរីកចម្រើនឡើងនូវលទ្ធភាពលើការស្រោចស្រពដី ដូចជាប្រព័ន្ធប្រឡាយ និងទំនប់ ស្តាក់ទឹកក៏ជាបច្ច័យមួយយ៉ាងសំខាន់ជំរុញឱ្យទិន្នផលស្រូវមានការកើនឡើងផងដែរ។ លោកប្រាប់ឱ្យដឹងថា : "ជាមធ្យម ប្រទេសកម្ពុជាមានសល់ស្រូវសម្រាប់នាំចេញប្រហែលជា ២លានតោន ក្នុងមួយឆ្នាំៗ។ ប៉ុន្តែនៅឆ្នាំនេះ ខ្ញុំរំពឹងថា ស្រូវសម្រាប់នាំចេញឆ្នាំក្រោយអាចលើសជាងនេះទៅទៀត"។**



Photo : P. Samphy

រូបភាពស្រូវក្នុងស្រែមួយនាខេត្តកំពង់ចាម ស្រូវសរីរាង្គកាន់តែមានសារៈសំខាន់ឡើងៗ ពីព្រោះស្រូវដែលប្រើប្រាស់ជីគីមីដោយគ្មានបទដ្ឋាន ស្រូវប្រើថ្នាំពុលសម្លាប់សត្វល្អិត និងស្រូវផ្លាស់ប្តូរសែន អាចធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកបរិភោគ

June-2009.qxd 5/30/2009 10:11 AM Page 10

## បទយកការណ៍

# ប្រជាជនក្រីក្រ ក៏មានសិទ្ធិទទួលបានសុភមង្គល ដូចគេដទៃដែរ

**ខាន់ ភីរម្យ**

ក្រោយពីត្រូវអាជ្ញាធរក្រុងនិងក្រុមហ៊ុន៧NG បានជម្លៀសចេញពីតំបន់ដីក្រហម កាលពីថ្ងៃទី២៤ ខែមករាមកប្រជាពលរដ្ឋមួយចំនួន ដែលម្ដុំគ្នារស់នៅខាងមុខបុរីសន្តិភាពនៅភូមិដំណាក់ទ្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កំពុងតែរង់ចាំដំណោះស្រាយ ក្រោយពីពេលដែលផ្ទះសម្បែងរបស់ពួកគេត្រូវរុះរើអស់។

អង្គុយនៅក្រោមខ្ទមប្រក់សំពត់តង់ ដែលមានទំហំមិនលើសពី ២ម៉ែត្របួនជ្រុង ស្ថិតនៅមុខបុរីសន្តិភាព លោកគឹម ស៊ីថា អាយុ ៤៣ឆ្នាំ អតីតអ្នករស់នៅក្នុងតំបន់ដីក្រហម បានឱ្យដឹងថា តាំងពីអាជ្ញាធរជម្លៀស មកកាន់តំបន់នេះ ពួកគេក៏កំពុងតែរស់នៅក្នុងភាពកណ្ដោចកណ្ដែង។

លោកគឹម ស៊ីថា ជាមេគ្រួសារ ដែលមានកូន៤នាក់ នៅក្នុងបន្ទុករស់នៅតំបន់ដីក្រហម ។គាត់ធ្លាប់មានមុខរបរជាអ្នកលក់កាហ្វេ ជាមួយនឹងប្រាក់ចំណូលមិនតិចជាង១០០០០០រៀលដែរ នៅក្នុងមួយថ្ងៃ។ ប៉ុន្តែនៅពេលនេះ សូម្បីតែ ២០០០០រៀល សឹងតែមិនបានដោយសារតែទីនេះនៅឆ្ងាយពីទីប្រជុំជន។ គាត់គឺជាប្រជាពលរដ្ឋម្នាក់ ដែលមានផ្ទះមួយ មានទំហំ៥x១២ម នៅក្នុងតំបន់ដីក្រហមដែលគេឈូសចោល។ ប៉ុន្តែជាអកុសលផ្ទះ ដែលគាត់មាននោះ គឺមិនមានចុះបញ្ជីនៅសហគមន៏ ឬក៏អាជ្ញាធរដែនដីត្រឹមត្រូវទើបបានជាគាត់ត្រូវបានគេចាត់ទុកថា ជាអ្នករស់នៅខុសច្បាប់ ហើយបង្ខំឱ្យមករស់នៅមុខបុរីសន្តិភាពនេះដោយមិនមានដំណោះស្រាយបែបនេះរហូតមកដល់សព្វថ្ងៃ។

លោកគឹម ស៊ីថា បានបញ្ជាក់ថា: "ខ្ញុំតស៊ូនៅទីនេះគឺចង់បានដីមួយដុំដើម្បីសង់ផ្ទះទុកឱ្យកូនរស់នៅតែប៉ុណ្ណោះ"។


ជីវភាពរស់នៅប្រចាំថ្ងៃរបស់អតីតអ្នកក្រីក្ររស់នៅដីក្រហម នៅភូមិដំណាក់ទ្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

Photo : L. Sovanna

### សាវតារតំបន់ដីក្រហម

**ប្រជាជនបានមកតាំងទីលំនៅតំបន់ដីក្រហមជិតស្ថានទូតរុស្ស៊ីកាលពីចុងឆ្នាំ២០០៣ ក្រោយពេលដែលសាលាក្រុងភ្នំពេញបានចេញសេចក្ដីជូនដំណឹងឱ្យប្រជាពលរដ្ឋដែលរស់នៅបែបអនាធិបតេយ្យនៅតំបន់ទន្លេបាសាក់ឱ្យមករស់នៅទីនេះ។ នៅក្នុងឆ្នាំ២០០៦ សាលាក្រុងបានចេញសារាចរមួយថ្មីដោយប្រគល់តំបន់នេះទៅក្រុមហ៊ុននៅក្នុងស្រុកមួយឈ្មោះ ៧NG ដើម្បីវិនិយោគ ហើយប្រជាជនដែលរស់នៅតំបន់នេះទាំងអស់ត្រូវតែរើចេញ ដែលជាហេតុបង្កើតឱ្យមានការតស៊ូរហូតដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩។ នៅចុងឆ្នាំ២០០៨ ប្រជាជនដែលគេគិតថាមានភាពស្របច្បាប់រស់នៅក្នុងតំបន់នេះចំនួន ១៩៦៥គ្រួសារ មានប្រជាពលរដ្ឋប្រមាណ ៩៣% បានយល់ព្រមចាកចេញជាថ្នូរនឹងប្រាក់សំណងដែលក្រុមហ៊ុនយល់ព្រមចំនួន ២០០០០ដុល្លារ ឬផ្ទះល្វែងមួយចម្ងាយ ១៦គម ពីចំណុចកណ្ដាលទីក្រុងភ្នំពេញទំហំ ៤x១២ម។**

សព្វថ្ងៃនេះលោកគឹម ស៊ីថា និងភរិយា នៅប្រកបរបរលក់កាហ្វេរបស់គាត់ដដែល ប៉ុន្តែគ្រាន់តែប្រាក់ចំណូលពីការលក់របស់គាត់ គឺមិនដូចមុនប៉ុណ្ណោះ។ ហើយសព្វថ្ងៃនេះកូនរបស់គាត់ទាំង២ នឹងប្រឈមមុខនឹងការឈប់រៀនដោយសារតែសាលារៀន គឺនៅជិតនឹងផ្ទះចាស់របស់ពួកគេឯណោះ។ លោកក៏បានបញ្ជាក់ថា: "ពួកគេត្រូវឈប់រៀនសិន ទំរាំខ្ញុំដូរសាលាឱ្យវាបាន"។

លោកយឹម សារឿន អាយុ៦១ឆ្នាំ ជាអ្នកដែលត្រូវគេជម្លៀសមកបុរីសន្តិភាពនេះ កាលពីថ្ងៃទី២៤ ខែមករាដែរនោះបានឱ្យដឹងថា នៅមុនពេលដែលមានការបង្ខំឱ្យពួកគេរើចេញពីតំបន់ដីក្រហមក្រុមហ៊ុន ៧NG ធ្លាប់សន្យា ប្រគល់ដីមួយប្លង់ដែលមានទំហំ ៥x២០ម ឱ្យពួកគាត់ដែរ។ តែដល់ពេលនេះ ហើយហាក់ដូចជាពុំឃើញសោះ ហើយក្ដីរំពឹងចុងក្រោយរបស់ពួកគាត់ថា នឹងបានដីនៅទីនោះមួយដុំដើម្បីកសាងផ្ទះនោះគឺហាក់ដូចជា កំពុងតែរសាត់ឆ្ងាយទៅៗ។ លោកបានបញ្ជាក់ថា: "មុនពេលគេដេញ គេធ្លាប់ទាំងដឹកពួកយើងទៅមើលដល់កន្លែងផង តែឥឡូវនេះ ស្ងាត់ជ្រាបអត់ដំណឹងសូន្យ"។

ដីដែលលោកយឹម សារឿន និងប្រជាពលរដ្ឋ ដទៃទៀត បានទៅមើលនោះ គឺវាមានទីតាំងនៅវិហារសួគ៌ដែលកាលនោះគេកំពុងតែឈូសឆាយ។ តាមទំនងដីមួយដុំនោះប្រហែលជាក្ដីរំពឹងចុងក្រោយនៃការតស៊ូរស់នៅអស់រយៈពេលប្រមាណ ៤ខែ របស់ប្រជាពលរដ្ឋប្រមាណជា២០០គ្រួសារចុងក្រោយដែលពុំទាន់មានដំណោះស្រាយនោះ ក្រោយពេលដែលប្រជាពលរដ្ឋមួយចំនួន ដែលមានលិខិតស្នាម និងបែបបទត្រឹមត្រូវ ត្រូវបានក្រុមហ៊ុនប្រគល់ផ្ទះមួយល្វែងនៅក្នុងបុរីសន្តិភាពនេះទំហំ៤x១២ម ឬទឹកប្រាក់ ១៥០០០ដុល្លារ និងក្រោយមកក្រុមហ៊ុនបានសន្យាតម្លើងប្រាក់រហូតដល់ ២០០០០ដុល្លារ។

លោកសារឿនបញ្ជាក់ថា: "យើងរស់នៅសំពត់តង់នេះ ដោយសារគ្មានជំរើស អ្នកខ្លះទ្រាំពុំបាន កំពុងតែដើរកកន្លែងអនាធិបតេយ្យថ្មីដើម្បីរស់នៅ"។

បើយោងតាមសំដីរបស់លោកសារឿន និងប្រជាពលរដ្ឋឯទៀត ដែលកំពុងតែរស់ នៅក្រោមសំពត់តង់នៅមុខបុរីសន្តិភាពនេះ បានឱ្យដឹងថា តាំងពីថ្ងៃទី២៤ ខែមករា មកពួកគេមិនទាន់បានទទួលអ្វីអំពីអាជ្ញាធរឬពីក្រុមហ៊ុននៅឡើយ។ សំពត់តង់ ដែលពួកគេកំពុងជ្រកនេះ គឺបានមកពីការឧបត្ថម្ភរបស់អង្គការមនុស្សធម៌តែប៉ុណ្ណោះ។

លោកយាយម្នាក់ដែលកំពុងតែបញ្ចុកបាយចៅ និងរស់នៅក្នុងតង់ជិតនឹងតង់របស់លោកគឹម ស៊ីថាដែរនោះ បានឱ្យដឹងថា គាត់មិនទទួលបានអ្វីសោះតាំងតែពីគេដឹកគាត់ និងចៅពីរនាក់មកទម្លាក់ នៅភូមិដំណាក់ទ្រយឹងនេះមក។

លោកយាយបានបញ្ជាក់ថា: "សូម្បីតែមួយរយក៏ខ្ញុំនិងកូនអត់បានទទួលដែរមកដល់ពេលនេះ"។ សព្វថ្ងៃនេះលោកយាយកំពុងតែរស់នៅជាមួយនឹងចៅពីរនាក់ ដោយកូនស្រីមេម៉ាយរបស់គាត់ ទៅរកស៊ីលក់បន្លែនៅផ្សារសន្សំកុសល។

លោកម៉ាន់ ឈឿន ជាអភិបាលរងរាជធានីភ្នំពេញ ដែលទទួលបន្ទុកកិច្ចការនេះ និងតំណាងក្រុមហ៊ុន ៧NG មិនអាចទំនាក់ទំនងសុំការបំភ្លឺបាន ។

ពាក់ព័ន្ធជាមួយនឹងការត្អូញត្អែរបស់ប្រជាពលរដ្ឋដែលកំពុងតែរស់នៅក្រោមសំពត់តង់ នៅពីមុខបុរីសន្តិភាពនាភូមិដំណាក់ទ្រយឹងនេះកាលពីថ្ងៃទី១១ ខែឧសភា កន្លងទៅ អង្គការសង្គមស៊ីវិលមួយចំនួនដែលរួមមានអង្គការការីតាស លីកាដូ ជាដើម បានរៀបចំនូវកិច្ចពិភាក្សាមួយដើម្បីរិះរកមធ្យោបាយជួយដល់សហគមន៍ក្រីក្រនោះ បន្ទាប់ពីត្រូវបានគេជម្លៀសមកភូមិដំណាក់ទ្រយឹងនេះតាំងតែពីថ្ងៃទី ២៤ ខែមករា មកនោះ។

លោកសុខ សាខន ប្រធានផ្នែកខាងគ្រប់គ្រងគ្រោះមហន្តរាយនៃអង្គការការីតាស មានប្រសាសន៍ថា កិច្ចប្រជុំនោះ ជាការជួបជុំគ្នាដើម្បីរកមធ្យោបាយជួយជនរងគ្រោះទាំងអស់នោះ។ តែទោះជាយ៉ាងណាក៏ដោយ អ្វីៗដែលអង្គការបានពិភាក្សាគ្នានោះភាគច្រើន គឺផ្អែកតែលើកម្មវិធីជំនួយផ្នែកមនុស្សធម៌មួយគត់។ លោកបន្តថា តាំងតែពីថ្ងៃទី២៤ ខែមករា ពេលពួកគេត្រូវបានក្រុមហ៊ុនបណ្ដេញចេញពីទីលំនៅមករស់នៅតំបន់ដីក្រហមមកនោះ រហូតដល់ថ្ងៃទី១ ខែកុម្ភៈ អង្គការការីតាសរបស់លោកក៏បានជួយពួកគេ តាមរយៈការចែកស្បៀងក្រោមគម្រោងជំនួយសង្គ្រោះជាបន្ទាន់មួយដែលមានទឹកប្រាក់១៥៩១៨ដុល្លារ រួចហើយ។

រហូតមកដល់ពាក់កណ្ដាលខែឧសភា នាឆ្នាំ២០០៩នេះ ជោគវាសនារបស់ប្រជាពលរដ្ឋទាំងអស់ចំនួន ២០០គ្រួសារ ដែលត្រូវបានគេបញ្ជូនមកកាន់ ភូមិដំណាក់ទ្រយឹង ខណ្ឌដង្កោ មានចម្ងាយប្រមាណជា ១៦គីឡូម៉ែត្រពីទីក្រុងភ្នំពេញនេះ នៅមិនទាន់ដឹងនៅឡើយ ហើយពួកគេក៏នៅតែបន្តរស់នៅក្រោមសំពត់តង់នៅរដូវវស្សាជាបន្តទៀត ខណៈដែលការសិក្សាពីអង្គការការីតាសនិងដៃគូ រកឃើញថា ពួកគេកំពុងប្រឈមមុខនឹងស្ថានភាពមួយដ៏លំបាក។

របាយការណ៍រួមគ្នាមួយរបស់អង្គការសង្គមស៊ីវិលចំនួន៨ ដែលរួមមានការីតាស មណ្ឌលនៃក្ដីសង្ឃឹម មជ្ឈមណ្ឌលព្យាបាលផ្លូវចិត្តកុមារ និងមនុស្សពេញវ័យ លីកាដូ ទស្សនៈពិភពលោក វីលិច អើដស៍ សាម៉ារីតាន់ភ័សនិងជេអរអេស ដែលបានប្រកាសកាលពីថ្ងៃទី១ ខែមេសាកន្លងទៅនេះបានឱ្យដឹងថា អស់រយៈពេលជាងពីរខែ គឺបន្ទាប់ពីការរុះរើផ្ទះសម្បែងទៅរស់នៅឯភូមិដំណាក់ទ្រយឹងនេះ ស្ថានភាពរស់នៅរបស់ពួកគេកំពុងតែជួបការលំបាកជាច្រើន។

ការសិក្សានោះ បានរកឃើញថា បញ្ហាដែលពួកគេកំពុងតែប្រឈមមុខខ្លាំងនោះ គឺជាបញ្ហាអនាម័យ ការបាត់បង់នូវលទ្ធភាពរកប្រាក់ចំណូល គ្មានជម្រកសមរម្យ កុមារបោះបង់ការសិក្សា និងបញ្ហាជំងឺផ្លូវចិត្តជាដើម។ របាយការណ៍នេះបានឱ្យដឹងថា បញ្ហាទាំងអស់នេះកំពុងតែគំរាមកំហែងដល់ពួកគេរៀងរាល់ថ្ងៃ ប្រសិនបើមិនមានដំណោះស្រាយ ។

ឆ្លងតាមរយៈរបាយការណ៍នៃការសិក្សារួមគ្នានេះ បណ្ដាអង្គការសង្គមស៊ីវិលទាំងនោះ បានផ្ដល់អនុសាសន៍មួយចំនួនដែលនៅក្នុងអនុសាសន៍ទាំងនោះ មានចំណុចមួយបានលើកឡើងថា ពួកគេគួរទទួលបានសំណងសមរម្យទៅលើទ្រព្យសម្បត្តិដែលបានខូចខាត និងបាត់បង់របស់ប្រជាជន។

### កាលប្រវត្តិនៃការបែងចែកដីនៅកម្ពុជា

**សកម្មភាពបែងចែកដីធ្លីនៅក្នុងប្រទេសកម្ពុជាហាក់ដូចជាស្មុគស្មាញ ហើយត្រូវបែងចែកជាដំណាក់កាលៗខុសៗគ្នា។ ចាប់តាំងពីឯករាជ្យពីបារាំង ពីឆ្នាំ១៩៥៣ មកដល់ឆ្នាំ១៩៧៥ ការបែងចែកដីធ្លីបានឡើងមួយដំណាក់។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៥-១៩៧៩ នៅក្រោមរបបខ្មែរក្រហម របបកម្មសិទ្ធិទាំងអស់ត្រូវបានលុបចោល។ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ការបែងចែកដីធ្លីត្រូវបានបែងចែកឡើងវិញ តែរដ្ឋនៅតែមានសិទ្ធិរុះរើកម្មសិទ្ធិនោះដដែល។**

**ក្នុងអំឡុងពេលនេះ កម្ពុជាបានបង្កើតច្បាប់ស្ដីពីកម្មសិទ្ធិឯកជន។ នៅក្នុងឆ្នាំ១៩៩២ គម្រោងបង្កើតទីផ្សារសេរី និងសិទ្ធិស្របច្បាប់លើទ្រព្យសម្បត្តិឯកជនក៏ចាប់ផ្ដើមលេចរូបរាងឡើង។ ក្រោយបោះឆ្នោតឆ្នាំ១៩៩៣ កម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់ដោយបរិបូរ។ ចាប់តាំងពីពេលនោះមក ទីផ្សារអចលនទ្រព្យក៏រីកចម្រើនរហូតដល់បង្កឱ្យមានទំនាស់រវាងពលរដ្ឋ និងក្រុមហ៊ុនវិនិយោគខ្លះៗ រហូតដល់សព្វថ្ងៃនេះ។**

June-2009.qxd 5/30/2009 10:11 AM Page 12



# យើងមានជំនឿលើព្រះជាម្ចាស់តាមវប្បធម៌របស់យើង

**យឹម ម៉ារី**

ទេវវិទ្យាល័យនៅទីក្រុងភ្នំពេញ មានរៀបចំសិក្ខាសាលាមួយស្ដីពីវប្បធម៌ទូទៅ ក្រោមការណែនាំ ពីលោកអភិបាលជនជាតិឥណ្ឌូថូម៉ាសម៉េណា ប៉ាណាប៉ារ៉ានទីល ។ អង្គសិក្ខាសាលានេះ បានប្រព្រឹត្តទៅចំនួនបីថ្ងៃ គឺចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ឧសភាកន្លងទៅ ដោយមានការអញ្ជើញចូលរួមពី លោកអភិបាលអេមីល ដេតម្បូនៃភូមិភាគភ្នំពេញ លោកអភិបាលអន់តូនីនៃភូមិភាគកំពង់ចាម លោកបូជាចារ្យ បងប្រុស បងស្រី ដែលមកពីព្រះសហគមន៍ផ្សេងៗ ទាំងបីភូមិភាគ សរុបចំនួន ៤០នាក់ ។

លោកអភិបាលជនជាតិឥណ្ឌូថូម៉ាស ម៉េណាប៉ាណារ៉ានទីល ក៏ដូចជាលោកបូជាចារ្យប្រ៊ុយណូ កូសម៉ី នាយកទេវវិទ្យាល័យបានមានប្រសាសន៍ថា ព្រះជាម្ចាស់ស្រលាញ់មនុស្សលោកខ្លាំងណាស់ ។ ហេតុនេះទើបបានជាព្រះអង្គចាត់ព្រះបុត្រាតែមួយ មកក្នុងលោកនេះសម្រាប់មនុស្សទាំងអស់ ពុំមែនសម្រាប់ប្រទេសមួយ ឬក៏ជនជាតិណាមួយនោះទេ ។ ដូច្នេះអស់អ្នកដែលជឿលើព្រះអង្គ អាចគោរព និងសរសើរតម្កើងព្រះអង្គតាមអារ្យធម៌របស់ខ្លួនបាន ។

ហើយយើងគួរតែបន្តប្រកាសផ្សាយដំណឹងល្អរបស់ព្រះជាម្ចាស់ទៅគ្រប់បណ្ដាប្រទេសនានាឱ្យសមស្របទៅនឹងវប្បធម៌អារ្យធម៌នៃប្រទេសនីមួយៗ ដើម្បីឱ្យគេមានភាពកក់ក្ដៅ ភាពស្និទ្ធស្នាល ហើយមានទំនុកចិត្តក្នុងការទទួលយកព្រះគ្រីស្ដ ចូលក្នុងដំណើរជីវិតរបស់ពួកគេម្នាក់ៗ ។



Photo : P. Samphy

**លោកអភិបាល លោកបូជាចារ្យ បងប្រុស បងស្រី និងគ្រីស្ដបរិស័ទថតរូបរួមគ្នាបន្ទាប់ពីសិក្ខាសាលាបានបញ្ចប់**

សិក្ខាសាលាក៏បានបញ្ចប់ដោយពិធីថ្វាយអភិបូជា ក្នុងបំណងអរព្រះគុណ ដល់ព្រះជាម្ចាស់ ដែលបានប្រទានពេលវេលាឱ្យបងប្អូន បានជួបពិភាក្សា និងរិះរកមធ្យោបាយក្នុងការផ្សព្វផ្សាយដំណឹងល្អទៅតាមលក្ខណៈវប្បធម៌នៃជនជាតិនីមួយៗ ។

# ពិធីគោរពមរណសាក្សីនៅព្រះសហគមន៍កាតូលិកបាត់ដំបង



Photo : Battembang

កាលពីថ្ងៃទី៨ ឧសភា ឆ្នាំ២០០៩ មនុស្សប្រមាណ ៤០០នាក់ បានចូលរួមគោរពដល់វិញ្ញាណក្ខន្ធមរណសាក្សីដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ក្នុងនោះមានលោកប៉ូលទេព អ៊ឹម សុត្ថា ជាអភិបាលនៃព្រះសហគមន៍ ភូមិភាគបាត់ដំបង និងលោកបូជាចារ្យហ្សង់ដែលត្រូវគេសម្លាប់ នៅភូមិក្បាលស្ពាន នាឃុំបត់ត្រង់ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ១៩៧៥ ។

កម្មវិធីនេះ មានការចូលរួមពីសំណាក់លោកអភិបាលគីកេ ហ្វីការេដូ លោកបូជាចារ្យ លោកនាយកសាលាបឋមសិក្សាក្បាលស្ពាន និងគ្រីស្ដបរិស័ទជាច្រើនរូបទៀត ។ ក្នុងកម្មវិធីនេះ ក៏មានការសម្ដែងរឿងពីអំពើឃោរឃៅខ្មែរក្រហមដែលបានសម្លាប់លោកអភិបាល និងជនរងគ្រោះផ្សេងៗទៀត ។

នេះគឺជាលើកទី២ហើយ ដែលព្រះសហគមន៍បាត់ដំបងប្រារព្ធកម្មវិធីនេះឡើងក្នុងគោលបំណងរំឭកដល់វិញ្ញាណក្ខន្ធនៃមរណបុគ្គល ដែលបានចែកឋាននៅក្នុង របបប្រល័យពូជសាសន៍ប៉ុលពត ព្រោះតែជំនឿ ។ លោកអភិបាលគីកេហ្វីការេដូ មានប្រសាសន៍ថា ថ្ងៃនេះ គឺជាថ្ងៃដែលយើងគួរចាប់អារម្មណ៍ពីការលះបង់ដើម្បីជំនឿ និងសេចក្ដីស្រលាញ់ តាមគំរូរបស់លោកអភិបាលប៉ូល ទេព អ៊ឹមផងដែរ ។

សូមបញ្ជាក់ កាលពីឆ្នាំ២០០០ សម្ដេចប៉ាបយ៉ូហានប៉ូលទី២ បានប្រកាសយកថ្ងៃទី៧ ឧសភា ធ្វើជាថ្ងៃប្រារព្ធពិធីគោរពមរណសាក្សីនៅលើពិភពលោក ។

**ដោយអរុណ និងសាមុត**

## កសិករក្រីក្រពង្រឹងកម្លាំងចិត្ត និងជំនឿតាមរយៈសន្តអ៊ីស៊ីដ័រ

កាលពីថ្ងៃទី១៥ ឧសភា កសិករក្រីក្រ និងគ្រីស្ដបរិស័ទប្រមាណជា ១០០នាក់ នៅព្រះសហគមន៍តាហែននាខេត្តបាត់ដំបង បានមកជួបជុំទទួលទឹកព្រះពរ និងថ្វាយអភិបូជានៅថ្ងៃបុណ្យរំឭកពីសន្តអ៊ីស៊ីដូរ៍ ជាឧបការីនៃកម្មករ និងកសិករ ។ នេះជាលើកដំបូងដែលព្រះសហគមន៍ប្រារព្ធពិធីនេះ ។

សន្តអ៊ីស៊ីដ័រ គឺជាគ្រីស្ដបរិស័ទម្នាក់ ដែលមានការតស៊ូក្នុងវាលស្រែ ទោះបីលោកឃើញស្រូវរបស់លោកមិនបានលូតលាស់ល្អក៏ដោយ ។ លោកគឺជាគ្រីស្ដបរិស័ទគំរូម្នាក់សម្រាប់ប្រជាកសិករក្រីក្រ ។

លោកគីមសួរ មានប្រសាសន៍ថា: "នៅឆ្នាំខ្លះនោះ យើងខំប្រឹងប្រែងធ្វើស្រែយ៉ាងខ្លាំង តែផលទទួលបានតិចតួចណាស់ដោយសារគ្រោះមហន្តរាយ ។ នៅពេលយើងជួបបញ្ហានេះ យើងងាយស្រួលនឹងបាក់ទឹកចិត្ត និងមានមន្ទិលសង្ស័យចំពោះព្រះជាម្ចាស់" ។ ប៉ុន្តែបុរសវ័យ ២៣ឆ្នាំរូបនេះ និយាយថា គាត់អាចយកឈ្នះលើអារម្មណ៍អវិជ្ជមានបាន នៅពេលលោកគិតអំពីសន្តអ៊ីស៊ីដូរ៍ដែលខំធ្វើស្រែយ៉ាងខ្លាំង និងបានអប់រំទូន្មានមនុស្ស ឱ្យចេះរស់ក្នុងជំនឿ និងអធិដ្ឋានជានិច្ច ។

លោកអភិបាលភូមិភាគបាត់ដំបង គីកេ ហ្វីការេដូ មានប្រសាសន៍ថា សន្តអ៊ីស៊ីដូរ៍ ជាមនុស្សសាមញ្ញម្នាក់ និងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវព្រះបន្ទូលដំណឹងល្អ ។ ដូច្នេះក្រុមគ្រួសារបព្វជិតមានតួនាទីសំខាន់អង្វរករព្រះជាម្ចាស់ដើម្បីជួយពួកគេឱ្យក្លាយជាកសិករឧស្សាហ៍ព្យាយាមដូចជាសន្តអ៊ីស៊ីដ័រ ដែលបានពង្រឹងកម្លាំងចិត្ត និងទទួលពរឱ្យស្រូវខ្លួន ។

**លី សុវណ្ណា**





# ប្រព័ន្ធធារាសាស្ត្រជាដំណក់នៃក្ដីសង្ឃឹម

**យី ម៉ារី**

ព្រះសហគមន៍តាហែននៃភូមិភាគបាត់ដំបង កំពុងរៀបចំប្រព័ន្ធធារាសាស្ត្រដើម្បីស្រោចស្រពលើផ្ទៃដី ១ម៉ឺនហិចតា ដែលអាចជួយដល់គ្រួសារកសិករប្រមាណ ៦០០គ្រួសារ ដើម្បីពួកគាត់អាចធ្វើស្រែបានគ្រប់រដូវ និងមានទឹកស្អាតប្រើប្រាស់ ។

គម្រោងការរៀបចំប្រព័ន្ធធារាសាស្ត្រថ្មីនេះ នឹងនាំមកនូវសេចក្ដីសង្ឃឹម ឱ្យដល់ប្រជាជននៅក្នុងតំបន់ដែលធ្លាប់ទទួលរងគ្រោះរាំងស្ងួតហួតហែង ធ្វើឱ្យដំណាំស្រូវទទួលរងការខូចខាត ដែលជំរុញឱ្យមានចំណាកស្រុករបស់ប្រជាជនទៅកាន់ប្រទេសថៃ ។

ហេតុដូច្នេះហើយ ទើបមានជាគម្រោង ដែលមានឈ្មោះថា ដំណក់នៃក្ដីសង្ឃឹម ។ វាជាគម្រោងដែលរៀបចំ និងសម្របសម្រួលដោយលោកប៉ាបប្លូ ហ្វីការេដូ ដែលត្រូវជាក្មួយប្រុសរបស់អភិបាល គីកេ ហ្វីការេដូ នៃភូមិភាគបាត់ដំបង ។

សូមបញ្ជាក់ថា គម្រោងនេះបានចំណាយទឹកប្រាក់សរុបចំនួន ១០ម៉ឺនដុល្លារ ដែលបានមកពី អ្នកលក់ទំនិញនៅទីក្រុងហ្ស៊ីហ្សុង (Gijon) របស់ប្រទេសអេស្ប៉ាញ និងក្លឹបហ្ស៊ីហ្សុង រ៉ូថារី (Gijon Rotary Club) ដែលជាហាងលក់ របស់របរសិប្បកម្ម និងវត្ថុអនុស្សាវរីយ៍មកពីប្រទេសកម្ពុជាកាសែតអេលកុំម៉ាស៊ីអូ (El Comercio) និងជំនួយឧបត្ថម្ភអំពីសប្បុរសជននានាជាច្រើនទៀត ។ គម្រោងនេះបានចាប់ផ្ដើមធ្វើពីកុម្ភៈ ឆ្នាំ២០០៩ ហើយក៏គ្រោងនឹងបញ្ចប់រួចរាល់នៅឆ្នាំ២០១១ ព្រោះការងារដំណើរការបានតែនៅក្នុងរដូវប្រាំងប៉ុណ្ណោះ ។



Photo : Pablo

**លោកអភិបាលភូមិភាគបាត់ដំបង គីកេ ហ្វីការេដូ កំពុងថតសកម្មភាពកសាងប្រព័ន្ធធារាសាស្ត្រ**

## ព្រះសហគមន៍កាតូលិក

# ភូមិភាគបាត់ដំបង

សៀវសាង ជាបព្វជិតសហជីវិនព្រះយេស៊ូម្នាក់ដែលបានមកតាំងលំនៅពីដំបូងនៅចុងសតវត្សរ៍ទី១៨ ។ លោកបានបង្កើតកម្មវិធីជួយអ្នកក្រីក្រ កុមារកំព្រា ចាស់ជរា និងជនពិការ ។ លោកបានដើរតួនាទីជាអ្នកបម្រើដោយពុំយកកម្រៃ ថែមទាំងបានទិញដីស្រែចំការជូនដល់បងប្អូនដែលនៅទីនោះ ដើម្បីឱ្យជីវភាពរស់នៅរបស់ពួកគេបានប្រសើរឡើង ។

នាចុងសតវត្សរ៍ទី១៩ ព្រះសហគមន៍បាត់ដំបងមានតែបងប្អូនជនជាតិវៀតណាមតែប៉ុណ្ណោះ ។ បន្ទាប់មកនៅឆ្នាំ១៩០៥ មានបងស្រី ២នាក់ ដែលមកពីក្រុមដូនជីឧបការគុណ បានស្ម័គ្រចិត្តធ្វើការនៅព្រះសហគមន៍ភូមិភាគបាត់ដំបង និងបានបើកមណ្ឌលកុមារកំព្រានិងមន្ទីរពេទ្យ ។ តែព្រះវិហារដែលបានសង់ឡើងឡើងនៅទីនោះត្រូវបំផ្លាញ ក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ។

ភូមិភាគមួយនេះត្រូវបានបង្កើតឡើងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៦៨ គឺក្រោមការមើលការខុសត្រូវពីសំណាក់លោកអភិបាល ប៉ូល ទេពអ៊ឹម សុត្ថា ។ តែដោយសារតែសង្គ្រាម ការទម្លាក់គ្រាប់បែក និងបន្តដោយរបបប្រល័យពូជសាសន៍ ប្រជាជនរាប់លាននាក់ត្រូវបានសម្លាប់ ក្នុងនោះមាន លោកអភិបាលប៉ូលទេពអ៊ឹម សុត្ថា និងលោកបូជាចារ្យយ៉ូហានប៉ាជ្រេ ដែលខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៥ នៅឃុំបត់ត្រង់ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ។

នៅដើមឆ្នាំ១៩៩០ ភូមិភាគនេះ ក៏បានចាប់កកើតឡើងវិញ ក្រោមការជួយណែនាំរបស់ក្រុមសាសនទូតក្រៅប្រទេសទីក្រុងប៉ារីស ។ អង្គការ JRS បានចូលមកក្នុងប្រទេសកម្ពុជាក្រោយមកប្ដូរជាJSC ។

ដោយសារក្រុមសហជីវិនព្រះយេស៊ូចាប់ផ្ដើមជាថ្មីនៅប្រទេសកម្ពុជា សម្ដេចប៉ាបបានសុំប្រធានក្រុមគ្រួសារបព្វជិតនេះ ដើម្បីជ្រើសតាំងលោកគីកេ ធ្វើអ្នកណែនាំភូមិភាគក្នុងនាមសម្ដេចប៉ាប ។ លោកគីកេត្រូវតែងតាំងនៅឆ្នាំ២០០០ ដើម្បីឱ្យទទួលខុសត្រូវនិងណែនាំភូមិបាត់ដំបង ។

រចនាសម្ព័ន្ធព្រះសហគមន៍កាតូលិកគឺមានលោកអភិបាលជាអ្នកណែនាំ ឬលោកបូជាចារ្យប្រចាំព្រះសហគមន៍នីមួយៗ ក្រៅពីនោះមានគណៈកម្មការសង្គហៈ គណៈកម្មការណែនាំអប់រំជំនឿ និងគណៈកម្មការពិធីបុណ្យសម្រាប់ការងារព្រះសហគមន៍ ។

**ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងបានចូលរួមចំណែកយ៉ាងច្រើនក្នុងការជួយជនក្រីក្រ និងសង្គមខ្មែរ។**



Photo : L. Sovanna

### សកម្មភាពជួយសង្គម

ព្រះសហគមន៍បាត់ដំបងមានសកម្មភាពដូចជាជួយសាងសង់សាលា ឧបត្ថម្ភនិស្សិត ជួយអ្នកជំងឺ អ្នកក្រីក្រ និងអភិវឌ្ឍន៍មូលដ្ឋាន-ល-។ បើនិយាយពីភូមិសាស្ត្រ ភូមិភាគបាត់ដំបងរួមមានខេត្តបាត់ដំបង សៀមរាប កំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង ព្រះវិហារ បន្ទាយមានជ័យ ប៉ៃលិន និងឧត្តមានជ័យ។ ភូមិភាគនេះមានព្រះសហគមន៍កាតូលិក ២៣កន្លែង និងមានគ្រីស្ដបរិស័ទប្រមាណជាង ៣០០០នាក់។

June-2009.qxd 5/30/2009 10:11 AM Page 14



# ពិធីតែងតាំងលោកចាប់ ជាបូជាចារ្យ ក្រុមយេស៊ូត

**លី សុវណ្ណា**

*ឆ្នាំ២០០៩-២០១០ ព្រះសហគមន៍កំណត់ជាឆ្នាំបូជាចារ្យ ។ ការតែងតាំងលោកចាប់ ជាបូជាចារ្យ នៅបាត់ដំបង នៅថ្ងៃទី២៤ ឧសភា កន្លងទៅ ។*



Photo : L. Sovanna

ក្បួនដង្ហែមុននឹងប្រារព្ធពិធីតែងតាំងលោកផុងផាន់ ភោគចារី ដែលមានគ្រីស្តបរិស័ទចូលរួមប្រមាណជាង ២០០០នាក់។



Photo : L. Sovanna

ពិធីអង្វរសន្តបុគ្គលសម្រាប់លោកបូជាចារ្យថ្មី ដឹកនាំដោយលោកអភិបាលភូមិភាគទាំងបី និងលោកបូជាចារ្យជាច្រើនអង្គ



Photo : L. Sovanna

លោកអភិបាលត្រាស់ហៅលោកឧបដ្ឋាកចាប់ក្នុងពិធីតែងតាំងលោកបូជាចារ្យថ្មី នៅព្រះសហគមន៍កាតូលិកបាត់ដំបង



Photo : L. Sovanna

ពិធីទ្រាប់ដៃជានិមិត្តរូបនៃការប្រទានព្រះវិញ្ញាណ ដើម្បីជាកម្លាំងចិត្តសម្រាប់លោកបូជាចារ្យថ្មីក្នុងការបំពេញមុខងារខ្លួន



Photo : L. Sovanna

មាតារបស់លោកបូជាចារ្យផុងផាន់ ភោគចារី ឬ លោកឪពុកចាប់ បំពាក់ស្បង់ថ្មីជូនដល់កូនក្រោយពេលតែងតាំងជាបូជាចារ្យថ្មី



Photo : L. Sovanna

កិច្ចស្វាគមន៍លោកបូជាចារ្យថ្មីអំពីសំណាក់លោកបូជាចារ្យផ្សេងៗ ដែលជាទម្លាប់ធម្មតាក្នុងពិធីតែងតាំងបូជាចារ្យ





# ព្រះសហគមន៍រំឭកដល់អ្នកស្លាប់ក្នុងរបបខ្មែរក្រហម

**លី សុវណ្ណា**

នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រះសហគមន៍កាតូលិក ក៏បានជួបជុំគ្នាធ្វើពិធីរំឭកវិញ្ញាណក្ខន្ធដល់លោកអភិបាលលោកបូជាចារ្យនិងបងប្អូនគ្រីស្តបរិស័ទទាំងឡាយ ដែលបានស្លាប់ក្នុងសម័យដ៏យង់ឃ្នងនេះ ។

គ្រីស្តបរិស័ទកាតូលិកប្រមាណជា ៤០នាក់ បានធ្វើដំណើរមកពីទីកន្លែងផ្សេងៗ ដើម្បីជួបជុំគ្នានៅភូមិតាំងគោក ឃុំស្រយោង ស្រុកបារាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី៧ ឧសភាកន្លងទៅ ។ ទីតាំងនេះដែលព្រះសហគមន៍កាតូលិកបានកំណត់ថាជា "ដីមរណសាក្សី" ឬ "ដីនៃសេចក្តីសង្ឃឹម" ។ នៅថ្ងៃនេះ គ្រីស្តបរិស័ទធ្វើអធិដ្ឋានជាពិសេស ដើម្បីឧទ្ទិសទៅដល់គ្រីស្តបរិស័ទទាំងអស់ នៅប្រទេសកម្ពុជាដែលបានស្លាប់យ៉ាងអយុត្តិធម៌នៅក្នុងរបបខ្មែរក្រហម ដែលបញ្ចប់នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ។

លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍កាតូលិកភូមិភ្នំពេញមានប្រសាសន៍ថា យើងមកជួបជុំគ្នានៅទីនេះដើម្បីរំឭកដល់លោកឆ្នា សាឡាស ជាអភិបាលព្រះសហគមន៍ភ្នំពេញពីដើម និងអស់អ្នកដែលបានបូជាជីវិត ដោយជំនឿទាំងអស់ ។ លោកអភិបាលអេមីល បានរំឭកឱ្យគ្រីស្តបរិស័ទរួមគ្នាអរព្រះគុណព្រះជាម្ចាស់ចំពោះកិច្ចដែលអស់អ្នកទាំងនោះបានបំពេញចំពោះព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ។ លោកបន្ថែមថា : "យើងត្រូវបន្តបេសកកម្មទាំងនោះពីគេ ដោយធ្វើជាសាក្សីរបស់ព្រះយេស៊ូ គឺស្រឡាញ់បងប្អូនឯទៀតៗ និងបម្រើអ្នកដទៃផង" ។

លោកតាឡាន អាយុ ៦៣ឆ្នាំ ជាគ្រីស្តបរិស័ទថ្មីនៅភូមិតាំងគោក និយាយថា : "ខ្ញុំមាននូវមោទនភាពណាស់ ពីព្រោះដោយសារលោកអភិបាលសាឡាសទើបមានព្រះសហគមន៍កាតូលិកតាំងគោកនេះ" ។

ព្រះសហគមន៍កាតូលិក រើសដីនៅឯភូមិតាំងគោកធ្វើជាដីមរណសាក្សីដោយសារភូមិសាស្ត្រនេះ មានប្រវត្តិដ៏ជិតស្និទ្ធទៅនឹងជីវិតរបស់លោកអភិបាលសាឡាស និងលោកបូជាចារ្យមួយចំនួនទៀតផង ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមដណ្តើមបានក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញ ។ អស់លោកទាំងនោះក៏បានធ្វើដំណើរមកតំបន់តាំងគោក ។

លោកស្រីយូ ប្រាកដ ជាប្អូនស្រីបង្កើតរបស់លោកអភិបាលឆ្នា សាឡាស ដែលបានរួមដំណើរ ចេញពីភ្នំពេញទៅតាំងគោក ពន្យល់បញ្ជាក់ថា : "លោកអភិបាល និងអស់លោកបូជាចារ្យទាំងអស់ត្រូវបានបង្ខំឱ្យធ្វើការងារជាទម្ងន់ ។ ម្យ៉ាងទៀតអស់លោកត្រូវបានស្នើសុំឱ្យរៀបការជាច្រើនលើកច្រើនសា ។ ប៉ុន្តែអស់លោកបដិសេធ (ដោយសារអ្នកបួស ក្នុងព្រះសហគមន៍កាតូលិក ពុំអាចមានគ្រួសារទេ)" ។

លោកអភិបាលទទួលមរណភាពនៅវត្តថ្លាក្នុងភូមិតាំងគោកដោយសារធ្វើការបាក់កម្លាំង ។

នៅដីមរណសាក្សី ក៏មានសង់ឈើឆ្កាងមួយយ៉ាងធំ និងផ្ទះដែលអស់លោកធ្លាប់បានស្នាក់នៅ ។ ក្នុងផ្ទះនេះ មានដាក់គ្រែដែលលោកអភិបាលធ្លាប់ប្រើនិងធ្លាប់ប្រារព្ធនូវពិធីអភិបូជា មុនពេលអស់លោកត្រូវចាកចេញ ពីភូមិតាំងគោក ទៅធ្វើការកន្លែងផ្សេង ក្រោយមកត្រូវបានសម្លាប់ និងស្លាប់ទាំងអស់ ។



Photo : L. Sovanna



Photo : L. Sovanna



Photo : L. Sovanna

June-2009.qxd 5/30/2009 10:11 AM Page 16



# លោកចាប់ : "យើងស្មើគ្នាចំពោះព្រះភក្ត្រព្រះជាម្ចាស់"

**លី សុវណ្ណា**



Photo : L. Sovanna

លោកផុងផាន់ ភោគថាវី ឬលោកឪពុកចាប់ ដែលទើបតែងតាំងថ្មីដើម្បីបម្រើសកម្មភាពព្រះសហគមន៍ភូមិភាគបាត់ដំបង

ក្នុងមុខងារថ្មីជាបូជាចារ្យ លោកផុងផាន់ ភោគថាវី "ចាប់" បញ្ជាក់ថា មិនមែនប្លែកអំពីមុនទេ គឺយើងត្រូវប្រកាសដំណឹងល្អ ដល់បងប្អូនទាំងអស់។ ប៉ុន្តែលោកមិនមែនជាមនុស្សពិសេស ឬខុសពីគ្រីស្តបរិស័ទធម្មតានោះទេ។ យើងមានឋានៈដូចគ្នាចំពោះព្រះភក្ត្រព្រះជាម្ចាស់ដែលព្រះអង្គគង់នៅជាមួយយើងគ្រប់ពេលវេលា។

លោកផុងផាន់ ភោគថាវី "ចាប់" ជាបូជាចារ្យថ្មីនៃក្រុមបព្វជិតសហជីវិនព្រះយេស៊ូ (Jesuit) ដែលត្រូវបានទទួលអគ្គសញ្ញាតែងតាំង កាលពីថ្ងៃទី២៤ ឧសភា កន្លងទៅ ដោយលោកអេមីល ដេតម្ប ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នៅព្រះសហគមន៍បាត់ដំបងក្រុង។ លោកបូជាចារ្យចាប់នឹងបំពេញមុខងារ បម្រើព្រះសហគមន៍កាតូលិក និងសង្គមក្នុងភូមិភាគបាត់ដំបង។

លោកបូជាចារ្យ (លោកឪពុកចាប់) បានចូលក្រុមបួសសហជីវិនព្រះយេស៊ូកាលឆ្នាំ២០០២។ លោកបានរៀបរាប់នូវ ប្រវត្តិនៃការត្រាស់ហៅថា លោកបានរិះគិតច្រើននៅពេលឃើញមនុស្សជាច្រើនរងទុក្ខវេទនា និងភាពអយុត្តិធម៌។ ប៉ុន្តែពួកគេនៅតែអាចញញឹមចេញបាន គឺ"គេនៅមានសេចក្តីសង្ឃឹមជានិច្ច"។ លោកបន្តថា លោកបានប្រៀបធៀប និងសួរខ្លួនឯងថា លោករស់ក្នុងក្រុមគ្រួសារដែលសុខសាន្ត តើខ្ញុំគួធ្វើអ្វីដែលមានប្រយោជន៍ និងអត្ថន័យពិតប្រាកដពិសេសឱ្យ "សមនឹងការប្រទានឱ្យរបស់ព្រះជាម្ចាស់"? តាមរយៈការរិះគិតនេះ លោកបានស្ម័គ្រចិត្តចូលក្រុមបួស គឺក្រុមបព្វជិតសហជីវិនព្រះយេស៊ូ គឺដោយក្រុមនេះបានធ្វើការច្រើនដើម្បីជួយជនរងគ្រោះ រងអយុត្តិធម៌ អ្នកក្រីក្រ និងអ្នកទទួលទុក្ខវេទនាដែរ។ ម្យ៉ាងទៀតដោយលោកឪពុកបានរៀនច្រើនពីអស់លោកជាបួសក្នុងក្រុមបព្វជិតនេះ ដែលតែងតែយកចិត្តទុកដាក់បម្រើបងប្អូនជានិច្ច គឺមិនដែលខ្លាចនឿយហត់ឡើយ។

លោកឪពុកចាប់ធ្លាប់ជាបុគ្គលិកបម្រើការនៅក្នុងអង្គការយេស៊ីតរយៈពេលជាង២០ឆ្នាំ។ លោកបានធ្វើការជាជិតស្និទ្ធជាមួយជនភៀសខ្លួន។ ក្នុងទសវត្សរ៍ទី៨០ លោកបានធ្វើការតាមជំរំជនភៀសខ្លួនខ្មែរនានាតាមបណ្តោយព្រំដែនខ្មែរ-ថៃ។ នៅពេលជនភៀសខ្លួនទាំងនោះ ធ្វើមាតុភូមិនិវត្តន៍ មកក្នុងកម្ពុជាវិញ លោកក៏បានចូលមកបម្រើ នៅប្រទេសកម្ពុជានៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលជនពិការ "បន្ទាយព្រាប" នៅឯស្រុកអង្គស្នួល ខេត្តកណ្តាល ពីឆ្នាំ១៩៩០ ដល់១៩៩៧។ ក្រោយមក លោកទៅជួយជនភៀសខ្លួនភូមា តាមព្រំដែនភូមា-ថៃ។

លោកឪពុកចាប់ជាជនជាតិថៃ និងសព្វថ្ងៃមានវ័យ ៥៣ឆ្នាំ។ លោកមាននូវមនោសញ្ចេតនាស្រឡាញ់យ៉ាងជិតស្និទ្ធជាមួយបងប្អូនប្រជាជនកម្ពុជា។

## ប្រតិទិនអភិបូជា

- ភាសាខ្មែរ : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- ភាសាបារាំង : Saturday of 1st week and 3rd week at 5:30pm; Sunday of 2nd and 4th week at 11:00 am; At St. Joseph Church, #1788B, NR5, PP.
- ភាសាអង់គ្លេស : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).







Photo : S. Philong

# អង្គុយបត់ជើងបញ្ជាក់ថា ខ្មែរជាជាតិមានឋានានុក្រមសង្គមច្បាស់

**ខាន់ ភីរម្យ**

លោកបណ្ឌិតមីសែល ត្រាណេ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រនិងវប្បធម៌ខ្មែរ បានមានប្រសាសន៍ថា អង្គុយបត់ជើងជាឥរិយាបថនៃការរស់នៅដ៏ថ្លៃថ្នូររបស់ជនជាតិខ្មែរ។ តាំងតែពីដើមរៀងមក ចំពោះគ្រួសារដែលទទួលបានការអប់រំតាមក្បួនសុជីវធម៌ខ្មែរច្បាស់លាស់ បែបបទនៃការរស់នៅដូចជាការផើបអង្គុយជាដើម គេតែងឃើញមានរបៀប និងបែបបទយ៉ាងត្រឹមត្រូវ។ ជាទូទៅក្មេងៗ នៅពេលដែលចូលរួមអង្គុយជាមួយនឹងអ្នកដែលមានវ័យចាស់ជាងខ្លួន ឬក៏អ្នកដែលមានឋានៈក្នុងគ្រួសារ ខ្ពស់ជាងខ្លួននោះ គេតែងតែអង្គុយបត់ជើងយ៉ាងទន់ភ្លន់ដែលឥរិយាបថទាំងនោះ កម្រនឹងបានជួប នៅក្នុងសង្គមដែលកំពុងតែរីកចម្រើននាពេលសព្វថ្ងៃនេះណាស់។

លោកបណ្ឌិតបានបញ្ជាក់ថា : "ការអង្គុយបត់ជើង ជាសុជីវធម៌ដ៏ប្រពៃមួយ មិនមានអ្វីមកកាត់ថ្លៃបាន របស់ជាតិសាសន៍ខ្មែរ។ នៅក្នុងសង្គមរស់នៅរបស់ ពលរដ្ឋសាមញ្ញរបស់ជនជាតិខ្មែរបុរាណ សុទ្ធតែមានក្បួនច្បាប់ និងក្រឹត្យក្រមយ៉ាងត្រឹមត្រូវតាំងតែពីការនិយាយស្តី ហូបចុក និងការអង្គុយជាដើម"។ លោកបានបន្តទៀតថា ការអង្គុយបត់ជើងនេះ គឺខ្មែរយើងបានអនុវត្តតាំងតែពីសម័យនគរភ្នំមកម្ល៉េះ ដោយមានការផ្សំគ្នារវាងវប្បធម៌របស់ខ្មែរ និងវប្បធម៌របស់ឥណ្ឌា។នៅមុនពេលដែលឥណ្ឌាបាននាំយកនូវវប្បធម៌មកសាបព្រោះក្នុងសង្គមកម្ពុជា គឺខ្មែរយើង មានរបៀបរបបនៃការអង្គុយនោះតាំងពីយូរហើយ។ គេក៏អាចរកឃើញឥរិយាបថនេះនៅសេសសល់ក្នុងប្រទេសកម្ពុជា ដល់សព្វថ្ងៃនេះ គឺការអង្គុយចោងហោង ឬអង្គុយពែនភ្នែនជាដើម។ ក្រោយមកនៅពេលដែលឥណ្ឌាចូលមកដល់ ខ្មែរក៏បានច្នៃរវាងការអង្គុយតាមបែបឥណ្ឌាមកជាការអង្គុយបត់ជើងតាមរបៀបខ្មែរវិញ។

លោកក៏បញ្ជាក់ទៀតថា : "អង្គុយបត់ជើងរបស់ឥណ្ឌាគឺអង្គុយអញ្ជលី។ រីឯអង្គុយបត់ជើងរបស់ខ្មែរវិញ គឺវាច្នៃចេញមកពីចោងហោង និងពែនភ្នែននេះឯង"។ លោកបន្តថា អង្គុយអញ្ជលីគឺខ្មែរយើងប្រើប្រាស់ដែរ តែពុំមែននៅក្នុងសង្គមជីវភាពសាមញ្ញ ឬក្នុងឥរិយាបថរស់នៅនោះទេ គឺការអង្គុយសំពះព្រះជាដើម។ រីឯការអង្គុយតាមបែបខ្មែរសុទ្ធសាធ ដូចជាការអង្គុយចោងហោងវិញ គឺគេឃើញនៅក្នុងពិធីសែនព្រេនរបស់បងប្អូនខ្មែរលើ ឬក៏អង្គុយផឹកស្រាជាដើម សម្រាប់ការពែនភ្នែន គឺទូទៅ។

## អំណាន

### រឿងបីនាក់ស្វែងរកសំណាង



បុរសបីនាក់ ភោគ សំណាងនិងរាសី ជាមិត្តជិតដិតនឹងគ្នា ហើយរស់នៅខេត្តបាត់ដំបង។ ពួកគេបីនាក់មានទុក្ខព្រួយរៀងៗខ្លួន។ ថ្ងៃមួយ ពួកគេទៅរកឱ្យគ្រូហោរទស្សន៍ទាយមើលជោគវាសនារបស់ខ្លួន។ ទំនាយរបស់គ្រូហោរថា : នាយភោគនឹងក្លាយជាអ្នកមាន។ នាយសំណាងក៏នឹងបានប្រពន្ធជាក្រមុំលក់ពោតស្ងោរនៅខេត្តបាត់ដំបង។ ចំណែកនាយរាសីនឹងស្លាប់នៅថ្ងៃរៀបការរបស់នាយសំណាង...។ ទីបំផុតពួកគេមកដល់ភ្នំពេញ។ ទំនាយរបស់គ្រូហោរចាប់ផ្តើមក្លាយជាការពិតបន្តិចម្តងៗ។ សម្រាប់អ្នកដែលមានវាសនាពុំសូវល្អ គេក៏ចាប់ផ្តើមបុកពោះអួចៗដែរ...។

រឿង បីនាក់ស្វែងរកសំណាង គឺជាប្រលោមលោកកំប្លែងសរសេរឡើង ដោយប្រើភាសាសាមញ្ញ រួមផ្សំជាមួយនឹងពាក្យកម្រងកែវសំបូរបែប។ សាច់រឿងទាក់ទាញប្រទាក់ក្រឡាគ្នា ធ្វើឱ្យយើងចង់អានរហូតដល់ចប់។

រឿងនេះនិពន្ធឡើងដោយលោកកែវ ច័ន្ទបូរណ៌ តាំងពីឆ្នាំ ១៩៨១ (កែសម្រួលឡើងវិញនៅឆ្នាំ២០០៤) ហើយត្រូវបោះពុម្ពដោយរោងពុម្ពកែវ មុណី (សហរដ្ឋអាមេរិក)។

### រឿងស្នេហាមួយ



បានកើតឡើង នៅពេលបុរសម្នាក់និងនារីម្នាក់ជួបគ្នា។ រឿងនេះមានដំណើរ គឺដូចជារឿងស្នេហាក្លាសិកមួយចំនួនដែរដោយចាប់ផ្តើមដំបូងពួកគេឈ្លោះប្រកែកគ្នា តែក្រោយមកគេចាប់ផ្តើមស្រឡាញ់គ្នា។ វាជាស្នេហាដ៏ធំ។ ឧបសគ្គរបស់ពួកគេសឹងតែគ្មាន។ ពួកគេគ្មានទាមទារអ្វីធំដុំទេក្នុងជីវិត : "គេរស់នៅគ្រាន់តែដើម្បីនឹងរស់តាមបង្គាប់ដួងចិត្តរបស់គេ... គេរៀនក៏ព្រោះតែគេចង់ចេះដឹងប៉ុណ្ណោះ"។

មើលទៅគឺហាក់ដូចជារឿងមួយធម្មតាៗ គ្មានអ្វីលេចធ្លោសោះ។ ប៉ុន្តែរឿងស្នេហាមួយអាចធ្វើឱ្យអ្នកអានសើចនិងយំក្នុងពេលជាមួយគ្នា និងអាចធ្វើឱ្យអ្នកអានខកចិត្ត នៅពេលដែលអ្វីៗគួរតែបានរៀបរយល្អ តែវាបែរជាខុសទំនងទៅវិញ។ ដោយតាមដានរឿងនេះ អ្នកអានអាចស្គាល់នូវនិយមន័យរបស់ជីវិតច្បាស់ជាងមុន (ក្នុងជីវិតមាសប្រាក់ កិត្តិយស... មិនសុទ្ធតែជាធាតុសំខាន់ទាំងអស់នោះទេ)។

រឿងនេះនិពន្ធឡើងដោយលោកអេរិក សីហ្គាល បកប្រែជា ភាសាខ្មែរដោយយី ឈាងអេង និងបោះពុម្ព តាំងពីឆ្នាំ ១៩៧៣ ដោយគ្រឹះស្ថាននគរធំ។

**ហួត សុជាតា**

## ប្រវត្តិសាស្ត្រ

# ម៉ាឡេស៊ីជារដ្ឋសហព័ន្ធដែលរីកចម្រើន

**ជាត សំភី**

តាមស្លាកស្នាមប្រវត្តិសាស្ត្រក៏បានបង្ហាញឱ្យឃើញនៅលើឧបទ្វីបម៉ាឡេស៊ី នៅរដ្ឋសាបា និងសារ៉ាវ៉ាក់ នូវក្រុមមនុស្ស សេម៉ាង ដែលមកមុនគេមកឈប់សំចតនៅប្រទេសម៉ាឡេស៊ី តាំងតែពី៥ម៉ឺនឆ្នាំ មុនគ្រិស្តសករាជមកម្ល៉េះ។ ពីសតវត្សទី២ដល់សតវត្សទី៣ ទឹកដីម៉ាឡេស៊ីគឺប្រមូលផ្តុំដោយរាជាណាចក្រតូចៗជាច្រើន ដែលមានរហូតដល់ទៅ៣០។

ពីសតវត្សរ៍ទី៨ ដល់សតវត្សរ៍ទី១៤ ព្រះរាជាណាចក្រនានានៃឧបទ្វីបម៉ាឡេ ដែលបានទទួលវប្បធម៌ប្រទេសឥណ្ឌាទាំងនោះ គឺត្រូវស្ថិតក្រោមការគ្រប់គ្រងក្នុងអធិបតេយ្យភាពរបស់ព្រះជាណាចក្រស៊ូម៉ាត្រា បន្ទាប់មកស្ថិតក្រោម ព្រះរាជាណាចក្រជ្វា ហើយនិងព្រះរាជានានារបស់សៀម។

នៅសហសវត្សរ៍ដំបូង ប្រជាជននៅឧបទ្វីបម៉ាឡេកាន់ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ ហើយលុះមកដល់ឆ្នាំ ១៤១៩ រាជាព្រះនាមប៉ារ៉ាមេស្វរៈ ដែលគ្រប់គ្រងក្រុងម៉ាឡាកា ដែលជាក្រុងកំពង់ផែយ៉ាងមមាញឹកជាងគេនៅអាស៊ីអាគ្នេយ៍ នាសម័យនោះបានប្តូរមកកាន់សាសនាឥស្លាម ហើយក៏កាន់ឋានៈជាស្តេចស៊ុលតង់។ រាជាណាចក្ររបស់ព្រះអង្គបានលាតសន្ធឹងគ្រប់គ្រងនៅលើឧបទ្វីបម៉ាឡេមានខេត្តប៉ាតានី (ភាគខាងត្បូងថៃបច្ចុប្បន្ន) រហូតដល់កោះស៊ូម៉ាត្រាភាគខាងកើត។ នៅឆ្នាំ១៥១១ ជនជាតិព័រទុយហ្គាល់ដណ្តើមយកស្ទើរកោះម៉ាឡាកា ហើយតាំងអាណានិគម។ នៅឆ្នាំ១៦៤១ ជនជាតិហូឡង់ដណ្តើមកន្លែងរបស់ព័រទុយហ្គាល។ នៅឆ្នាំ ១៩៣០ រដ្ឋម៉ាឡាកា ប៉េណាំង និងសិង្ហបុរី បង្កើតបានជាគ្រឹះស្ថានសាធារណៈច្រកសមុទ្រ ដែលក្លាយជាអាណានិគមរបស់អង់គ្លេស នៅឆ្នាំ១៨៦៧។ ពីឆ្នាំ១៨៦៧ ដល់ឆ្នាំ១៩១៤ រដ្ឋបាលអង់គ្លេសក៏បានលាតសន្ធឹងទៅគ្រប់រាជាណាចក្រស៊ុលតង់ម៉ាឡេ។ រដ្ឋបាលនេះបានធ្វើការអភិវឌ្ឍន៍យ៉ាងខ្លាំងលើការនាំចេញនូវសំណប៉ាហាំង និងកៅស៊ូ។

ពីឆ្នាំ១៩៤២ ដល់១៩៤៥ ជប៉ុនក៏បានមកគ្រប់គ្រងឧបទ្វីបម៉ាឡេ ហើយក្រោយមក ក៏ដកថយដោយសារចាញ់សង្គ្រាមលោកទីពីរ។ នៅឆ្នាំ១៩៥៧ រដ្ឋសហព័ន្ធម៉ាឡេបានទទួលនូវឯករាជ្យភាពនៅក្នុងក្របខណ្ឌកុំមូនវែល ដែលជាក្រុមប្រទេសនិយាយភាសាអង់គ្លេស។ លោកអាល់ដុល រ៉ាម៉ាន់ ក៏បានក្លាយជានាយករដ្ឋមន្ត្រី។ នៅឆ្នាំ១៩៦៣ រដ្ឋសហព័ន្ធម៉ាឡេស៊ីប្រមូលផ្តុំម៉ាឡេស៊ីដីគោក សិង្ហបុរី រដ្ឋសារ៉ាវ៉ាក់ និងភាគខាងជើងនៃកោះប័រណេអូ។ នៅឆ្នាំ១៩៦៥ សិង្ហបុរីបានដកខ្លួនពីសហព័ន្ធម៉ាឡេ។ នៅឆ្នាំ១៩៧០ លោកអាប់ដុល រ៉ាហ្សាក់ ក៏បានធ្វើជានាយករដ្ឋមន្ត្រី បន្តអំពីលោកអាប់ដុល រ៉ាម៉ាន។ ប្រទេសម៉ាឡេស៊ី បានជួបវិបរីត ដោយសារជម្លោះរវាងជនជាតិម៉ាឡេ និងសហគមន៍ជនជាតិចិន ការបះបោល របស់លទ្ធិកុំម្មុយនីស្ត និងលំហូចូលនៃជនភៀសខ្លួនពីប្រទេសកម្ពុជា និងវៀតណាម (ចាប់តាំងពីឆ្នាំ១៩៧៩)។

នៅឆ្នាំ១៩៨១ លោកម៉ាហាធៀ ប៊ិន ម៉ូហាមេឌ ក៏បានក្លាយជានាយករដ្ឋមន្ត្រី។ សេដ្ឋកិច្ចនៃប្រទេសម៉ាឡេស៊ីបានអភិវឌ្ឍយ៉ាងរហ័ស ពីព្រោះម៉ាឡេស៊ីគឺជារដ្ឋមួយក្នុងចំណោមរដ្ឋទាំងបីដែលគ្រប់គ្រងច្រកសមុទ្រម៉ាឡាកា ដែលនេះជំរុញឱ្យមានការរីកចម្រើនខាងពាណិជ្ជកម្មអន្តរជាតិ។




Photos : DR

### អំពីប្រទេសម៉ាឡេស៊ីនាបច្ចុប្បន្ន



**រដ្ឋសហព័ន្ធនៃតំបន់អាស៊ីអាគ្នេយ៍ ដែលបង្កើតឡើងដោយដីទ្វីបមួយផ្នែក (ម៉ាឡេស៊ីបស្ចិម ឬឧបទ្វីប) និងដីកោះ (ម៉ាឡេស៊ីបូព៌ា) ដែលស្ថិតនៅលើកោះប័រណេអូ ដែលមានរដ្ឋសាបា និងសារ៉ាវ៉ាក់។ ផ្ទៃដីមានទំហំ ៣៣០០០០ គម²។ ប្រជាជនមាន ២៥០០០ ០០០នាក់។ រាជធានី គឺកូឡាឡាំពួរ។ ភាសា គឺម៉ាឡេ។ រូបិយវត្ថុគឺដុល្លារម៉ាឡេស៊ី។ រដ្ឋស្ថិតនៅអាកាសធាតុត្រូពិក គឺឈរលំដាប់លេខមួយខាងផលិតផលកៅស៊ូ (ធម្មជាតិ) និងសំណប៉ាហាំង។ ក្រោមដីនៅមានរ៉ែបុកស៊ីត និងជាពិសេសប្រេងកាត។ ស្រូវគឺជាអាហារមូលដ្ឋានរបស់ប្រជាជនដែលប្រមូលនៅម៉ាឡេស៊ីបស្ចិម។**



## អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

### បុណ្យគោរពព្រះត្រៃឯក (ថ្ងៃទី០៧ កក្កដា ឆ្នាំ២០០៩)

(គម្ពីរដំណឹល្អតែងដោយលោកម៉ាថាយ ២៨,១៦-២០)

ថ្ងៃអាទិត្យនេះព្រះសហគមន៍ធ្វើបុណ្យលើកតម្កើងព្រះត្រៃអង្គ ដែលមានន័យថា ព្រះជាម្ចាស់តែមួយព្រះអង្គគត់ពិតជាព្រះបិតារបស់យើង។ ព្រះបិតាជាប្រភពនៃជីវិតគ្រប់យ៉ាង និងគឺជាអ្វីៗសព្វសារពើដែរ។ នៅពេលព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង ព្រះអង្គបានប្រទានសេចក្តីសុខសាន្តដល់ក្រុមសាវ័ក ព្រមទាំងចាត់គេឱ្យប្រកាសផ្សាយដំណឹងល្អ និងធ្វើបុណ្យកំណើតថ្មីជូនអ្នកដែលស្ម័គ្រចិត្តធ្វើជាសាវ័ក។ បេសកកម្មនេះនាំឱ្យសាវ័កប្រកាសដំណឹងល្អ និងធ្វើពិធីជ្រមុជទឹកដល់អ្នកថ្មីដើម្បីប្រកាសដំណឹងល្អ ដែលមិនត្រឹមតែពាក្យសំដី គឺមានទាំងសកម្មភាពផងដែរ។

ជំនឿលើព្រះជាម្ចាស់ នាំឱ្យយើងមានសេរីភាព និងចាកចេញអំពីការភ័យខ្លាច។ យើងមិនមែនជាខ្ញុំបម្រើដាច់ថ្លៃនោះទេ ប៉ុន្តែយើងជាបុត្រដ៏ជាទីស្រលាញ់នៃព្រះបិតា។ យើងមិនរស់នៅក្រោមអំណាចមន្តអាគម និងមិនរំពឹងទៅលើកាអស្ចារ្យណាមួយឡើយ តែយើងធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងអនុវត្តទៅតាមសេចក្តីស្រលាញ់ ព្រមទាំងមានភាពយុត្តិធម៌ផង។

### បុណ្យលើកតម្កើងព្រះកាយ និងព្រះលោហិតព្រះគ្រិស្ត (ថ្ងៃទី១៤ មិថុនា ឆ្នាំ២០០៩)

(គម្ពីរដំណឹងល្អតែងដោយសន្ត ម៉ាកុស ១៤,១២-១៦,២២-២៦)

ព្រះយេស៊ូត្រៀមខ្លួនសម្រាប់ថ្ងៃចុងក្រោយ។ ព្រះអង្គគង់នៅជាមួយមិត្តភក្តិ។ អ្វីៗទាំងអស់បានត្រៀមរួចជាស្រេច។ អាហារពេលចុងក្រោយដែលព្រះយេស៊ូអញ្ជើញឱ្យសាវ័កមកទទួល ជាអំណោយនៃជីវិតដែលគិតមិនដល់។ ព្រះយេស៊ូប្រាប់ថា "នេះជារូបកាយរបស់ខ្ញុំ..." "នេះជាលោហិតរបស់ខ្ញុំ..." សូមទទួលយកទៅពិសាឱ្យបានគ្រប់គ្នាទៅ។ ព្រះយេស៊ូត្រូវប្រឈមមុខនឹងភាពងងឹតនៃកាលវេលាចុងក្រោយ ដោយរង់ចាំជាមួយនិងមិត្តភក្តិរបស់ព្រះអង្គ។

នៅក្នុងអភិបូជា យើងរួមគ្នាចែកនំបុ័ង និងអ្វីៗដែលបានទទួលពីព្រះអង្គ ដែលជាការចែកជីវិត និងញើសឈាម...។ ដូច្នេះពេលថ្វាយអភិបូជា យើងមិនគ្រាន់តែនឹករលឹកពីព្រះគ្រិស្តដែលគង់ជាមួយយើងប៉ុណ្ណោះទេ គឺយើងសូមចូលរួមជាមួយព្រះយេស៊ូដែលបូជាព្រះជន្មផងដែរ។

### ថ្ងៃអាទិត្យទី១២ ក្នុងរដូវធម្មតា (ថ្ងៃទី២១ មិថុនា ឆ្នាំ២០០៩)

*ជំនឿ និងការភ័យខ្លាច* (ដំណឹងល្អតាមសន្តម៉ាកុស ៤,៣៥-៤១)

សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ផ្តល់កម្លាំង និងភាពក្លាហានឱ្យយើងដើរទៅមុខជាមួយព្រះយេស៊ូ។ ជាមួយព្រះយេស៊ូ អ្វីៗទាំងអស់សុទ្ធតែកើតថ្មី។ តាមធម្មតា យើងភ័យខ្លាចសេចក្តីថ្មីៗ ពីព្រោះយើងមានភាពងាយស្រួលនៅក្នុងទម្លាប់ចាស់។ ប៉ុន្តែព្រះបន្ទូលផ្តល់ជីវិត និងមានសោភ័ណភាពថ្មី។ ប្រសិននរណាម្នាក់រួមជាមួយព្រះគ្រិស្ត អ្នកនោះបានកើតជាថ្មី និងអ្វីៗពីអតីតកាលបានកន្លងផុតទៅ។ អ្វីៗទាំងអស់ប្រែជាថ្មីវិញ (២.ករ៥,១៧)។ នៅក្នុងអង្គព្រះគ្រិស្ត យើងត្រូវមានសេចក្តីស្រលាញ់ថ្មី ដោយបម្រើអ្នកដទៃជួយអ្នកក្រីក្រ និងអ្នកកំសត់ទុរគត ។ល។ លោកយ៉ូបប្រាប់ថា: សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់លើអ្វីៗទាំងអស់។ តែយើងក៏ត្រូវការបើកដួងចិត្តទទួល និងសូមឱ្យបើកដួងចិត្តទទួលបងប្អូនឯទៀតៗ។ ប្រសិនយើងមានជំនឿ ការភ័យខ្លាចនឹងចាកចេញហើយយើងក៏មានសេចក្តីសុខសាន្តគ្រប់ពេលវេលាដែរ។

### បុណ្យរំលឹកសន្តសីលា និងសន្តប៉ូល (ថ្ងៃ២៨ មិថុនា ឆ្នាំ២០០៩) (ម៉ាថាយ ៤,៣៥-៤១)

ថ្ងៃអាទិត្យនេះព្រះសហគមន៍ឱ្យយើងធ្វើបុណ្យរំលឹកសន្តសីលា និងសន្តប៉ូល។ សន្តសីលាជាអ្នកទទួលមុខងារក្នុងព្រះសហគមន៍មុនដំបូងជាបង្គោលនៃជំនឿ ដោយបានប្រកាសដំណឹងល្អ ដល់ជនជាតិអ៊ីស្រាអែល ហើយជាអ្នកកាន់កូនសោនៃស្ថានបរមសុខដែរ។ ចំណែកសន្តប៉ូលវិញ លោកជាអ្នកប្រកាសដំណឹងល្អព្រមតាំងការពារជំនឿរបស់ព្រះសហគមន៍។ លោកប៉ូលជាគ្រូ និងជាអ្នកប្រាជ្ញ បានណែនាំឱ្យមនុស្សគ្រប់ជាតិសាសន៍ចូលក្នុងព្រះសហគមន៍។ ដូច្នេះហើយសន្តសីលា និងសន្តប៉ូលមានគោលបំណងតែមួយដូចគ្នា គឺនាំឱ្យមនុស្សទាំងអស់បានទទួលការសង្គ្រោះក្នុងព្រះរាជ្យព្រះជាម្ចាស់។

សព្វថ្ងៃ គ្រិស្តបរិស័ទម្នាក់ៗមានមុខងារផ្សេងពីគ្នាក្នុងការប្រកាសដំណឹងល្អ តែមានគោលដៅ និងបំណងដូចគ្នា។ ចូរយើងទាំងអស់គ្នាសូមអង្វរព្រះជាម្ចាស់តាមរយៈសន្តសីលា និងសន្តប៉ូលឱ្យព្រះសហគមន៍ និងគ្រិស្តបរិស័ទចេះប្រកាសដំណឹងល្អ និងមានសេចក្តីស្រលាញ់របស់ព្រះអង្គ ដល់បងប្អូនជនជាតិខ្មែរផង។

***(អ្នកនាំសារ ខែមិថុនា ២០០៩ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកបូជាចារ្យ អុន សុន)***

## យើងអាន



Photo: M. Kunthear

សួស្តីប្អូនៗ

ឆ្នាំនៃសន្តប៉ូលនឹងត្រូវបិទនៅថ្ងៃទី២៧ ខែមិថុនា ខាងមុខនេះ។ ក្នុងមួយឆ្នាំនេះ ប្អូនៗបានរៀបចំ និងរៀនអំពីបទពិសោធន៍របស់លោកប៉ូលបានអ្វីខ្លះ?

យើងបានទទួលស្គាល់ហើយថា លោកជាគ្រិស្តទូតមួយរូបដែលបានចេញប្រកាសដំណឹងល្អនៅទីកន្លែងដាច់ស្រយាលលើផែនដី។ លោកបានបង្រៀនមនុស្សជាច្រើនឱ្យដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ គឺសុខចិត្តជឿលើព្រះយេស៊ូជាព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់ជាបិតា។ ព្រះយេស៊ូបានទទួលរងទុក្ខលំបាកគ្រប់បែបយ៉ាងរហូតដល់សោយទិវង្គតនៅលើឈើឆ្កាង។ នៅថ្ងៃទីបីព្រះជាម្ចាស់បានប្រោសព្រះអង្គឱ្យមានព្រះជន្មថ្មីដ៏រុងរឿងដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ សន្តប៉ូលបានបន្តបេសកកម្មនេះរហូតដល់ត្រូវគេសម្លាប់នៅទីក្រុងរ៉ូម។ លោកប្រកាសដំណឹងល្អអំពីការសង្គ្រោះរបស់ព្រះជាម្ចាស់ និងសេចក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះមនុស្សលោកគ្រប់ជាតិសាសន៍។ ទោះបីលោកស្ថិតនៅក្នុងមន្ទីរឃុំឃាំង លោកនៅតែបន្តសរសេរសំបុត្រផ្ញើទៅកាន់គ្រិស្តបរិស័ទតាមព្រះសហគមន៍នានាដែលលោកបានទៅដល់ដើម្បីលើកទឹកចិត្តដល់គេឱ្យចាប់អារម្មណ៍រស់នៅឱ្យសមជាបុត្រធីតារបស់ព្រះជាម្ចាស់ និងឱ្យស្របតាមព្រះបន្ទូល។ លោកបានរស់នៅជាគ្រិស្តបរិស័ទគំរូមួយរូប។

តើប្អូនបានចាំនូវប្រវត្តិរបស់ប៉ូលឬទេ? តើព្រះជាម្ចាស់ត្រាស់ហៅលោកដោយរបៀបណា? ពីដំបូងលោកបានប្រឆាំងនឹងព្រះសហគមន៍យ៉ាងខ្លាំងខ្លា និងបៀតបៀនគ្រិស្តបរិស័ទផង។ លោកជាអ្នកកាន់តាមវិន័យលោកម៉ូសេយ៉ាងខ្ជាប់ខ្ជួនផងដែរ។ ក្រោយមកព្រះយេស៊ូបានត្រាស់ហៅលោកឱ្យទៅជាអ្នក ដែលប្រកាសដំណឹងល្អអំពីព្រះយេស៊ូទៅមនុស្សវិញ។ ដូច្នេះជីវិតលោកត្រូវប្រែប្រួលភ្លាមៗ តែគ្រិស្តបរិស័ទមួយចំនួនមិនសូវទុកចិត្តលើលោកប៉ូលផងដែរ។ សូមប្អូនៗធ្វើតាមគំរូរបស់លោកប៉ូល គឺរស់នៅដោយស្រឡាញ់បងប្អូនមិត្តភក្តិ គោរពចាស់ទុំលោកគ្រូឪពុកម្តាយ និងខិតខំរៀនសូត្រជាដើម។

លី សុវណ្ណា

# ល្បែងកំសាន្ត ចំនុចខុស

សូមប្រិយមិត្តជួយស្វែងរកចំនុចខុសគ្នាទាំង ៧ សម្រាប់រូបខាងក្រោម!



Photo : DR

## កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"

រៀបចំឡើងដោយការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកដើម្បីបង្ហាញផ្លូវ និងជួយស្វែងរកដំណោះស្រាយដល់មិត្តយុវវ័យលើបញ្ហាមួយចំនួនមានដូចជា បញ្ហាសង្គម ចិត្តសាស្ត្រ និងទំនាក់ទំនងយុវវ័យ-ល-។ កម្មវិធីនេះមានផ្សាយផ្ទាល់រាល់ថ្ងៃច័ន្ទ និងអង្គារ វេលាម៉ោង ១០-១១ព្រឹក នៅវិទ្យុគ្រួសារ FM 99.5 Mhz រាជធានីភ្នំពេញ ។

## ការងារប្រចាំខែ

- ថ្ងៃទី១ មិថុនា : ការប្រារព្ធទិវាសិទ្ធិកុមារអន្តរជាតិរៀបចំដោយភូមិភាគកំពង់ចាម ដែលមានកុមារចូលរួមចំនួន១២០០នាក់ នៅបីកន្លែង ព្រះសហគមន៍ព្រៃវែង ព្រះសហគមន៍អ្នកលឿង និងព្រះសហគមន៍ចំការទៀង។
- ថ្ងៃទី១ មិថុនា : ការប្រជុំក្រុមអន្តរនិកាយសាសនា ដែលរៀបចំធ្វើឡើង នៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី២-៥ មិថុនា : សិក្ខាសាលាសម្រាប់គ្រូអប់រំជំនឿចំនួន២០នាក់ ក្រោមប្រធានបទការដោះស្រាយទំនាស់នៅក្នុងសង្គមដែលរៀបចំធ្វើឡើងនៅកំពង់ចាម។
- ថ្ងៃទី៧ មិថុនា : ពិធីសច្ចាលើកទីមួយរបស់នីរសពីររូប មកពីក្រុមគ្រួសារបងស្រីឧបការ-គុណរៀបចំធ្វើឡើង នៅព្រះវិហារព្រះកុមារយេស៊ូ នៃព្រះសហគមន៍កាតូលិកបឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី៨-១៣ មិថុនា : សំណាក់ធម៌របស់ក្រុមបូជាចារ្យដែលរៀបចំឡើងនៅព្រះសហគមន៍កំពង់សោម។
- ថ្ងៃទី១៤ មិថុនា : ពិធីទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្តលើកទី១ នៃភូមភាគភ្នំពេញនៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី១៩ មិថុនា : ពិធីបុណ្យរំឭកខួបលើកទី១៥០ឆ្នាំ នៃសន្តយ៉ូហាន ម៉ារីវីយ៉ាណេ និងពិធីបើកឆ្នាំបូជាចារ្យ ដែលរៀបចំធ្វើឡើងនៅទេវវិទ្យាល័យ រាជធានីភ្នំពេញ។
- ថ្ងៃទី២០ មិថុនា : ការប្រជុំអ្នកដឹកនាំដែលមានការអញ្ជើញគណៈកម្មការចំនួនពីររូប តាមព្រះសហគន៍នីមួយៗ ចំនួន៨ នៃព្រះសហ-គមន៍កាតូលិកភូមិភាគភ្នំពេញ។
- ថ្ងៃទី២៤ មិថុនា : ប្រជុំរបស់លោកបូជាចារ្យ និងបងស្រី ព្រមទាំងទទួលគណៈកម្មការពិធីបុណ្យអន្តរភូមិភាគ ដែលរៀបចំធ្វើឡើងនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី២៧ មិថុនា : ការប្រារព្ធពិធីបិទឆ្នាំនៃសន្តប៉ូលធ្វើឡើងនៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី១៨-១៩ កក្កដា : សិក្ខាសាលាអំពីចិត្តគំនិតនៃអ្នកអប់រំជំនឿ នៃភូមិភាគភ្នំពេញ និងកំពង់ចាម ដែលមានអ្នកចូលរួមចំនួនពី៥០-៦០នាក់ នៅព្រះសហគមន៍កំពង់ចាម។